ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការសកម្មភាពអនុវត្តគោលនយោបាយស្តីពី
# ការផ្តល់អាហារតាមសាលារៀន




ខែតុលា ឆ្នាំ២០២៥

# មាតិកា


បុព្វកថា ..................................................... ១

១. សាវតារ ..................................................... ៣

១.១. គោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀន ..................... ៩

១.២. ស្ថានភាព ..................................................... ៩

១.៣. អាទិភាព ..................................................... ១៦

២. យុទ្ធសាស្ត្រ ..................................................... ១៩

៣. តារាងម៉ាទ្រិកផែនការសកម្មភាពអនុវត្តគោលនយោបាយ ..................... ២៣

៤. ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ..................................................... ៦៤

៥. តម្រូវការថវិកា ..................................................... ៦៨

៥.១. តម្រូវការថវិកាតាមយុទ្ធសាស្ត្រ ..................................................... ៦៨

៥.២. តម្រូវការថវិកាតាមក្រសួង ស្ថាប័ន ..................................................... ៦៩

៦. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ..................................................... ៧០

៧. ចំណុចផ្តោតផែនការសកម្មភាពតាមដំណាក់កាល ..................................................... ៧៣

៨. សេចក្តីសន្និដ្ឋាន ..................................................... ៧៣

ពាក្យកាត់ និងអក្សរកាត់ ..................................................... ៧៤

សន្ទានុក្រម ..................................................... ៧៥

# បុព្វកថា

រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភាបានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ដោយកំណត់យកអាទិភាពគន្លឹះចំនួន៥ រួមមាន មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា។ ការអភិវឌ្ឍមូលធនមនុស្សគឺជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបានសម្រាប់ជំរុញពិពិធកម្មនិងកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន និងភាពធន់។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបន្តជំរុញការអភិវឌ្ឍមូលធនមនុស្ស និងសុខុមាលភាពពលរដ្ឋតាមរយៈការបន្តជំរុញការអនុវត្តប្រព័ន្ធគាំពារសង្គមឱ្យកាន់តែរឹងមាំ ដោយជំរុញការអនុវត្តគោលនយោបាយស្តីពី ការផ្តល់អាហារតាមសាលារៀនឆ្នាំ២០២៤-២០៣៥។

ដើម្បីអនុវត្តគោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀនឱ្យទទួលបានជោគជ័យតាមផែនការកំណត់ និងក្របខ័ណ្ឌពេលវេលាជាក់ស្តែង គណៈកម្មការដឹកនាំនិងគ្រប់គ្រងការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនបានរៀបចំផែនការសកម្មភាពឆ្លើយតបទៅនឹងយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្ររងនៃគោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀនជាមគ្គុទេសក៍សម្រាប់អនុវត្តសកម្មភាពជាក់ស្តែងប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។

ប្រការនេះ ទាមទារឱ្យមានការចូលរួមគាំទ្រយ៉ាងពេញទំហឹងពីគ្រប់ភាគីពាក់ព័ន្ធ និងសហគមន៍សំដៅសម្រេចគោលដៅអាទិភាពចំនួន៧ ក្នុងចំណោម១៨ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០៣០ ដូចជា គោលដៅទី១៖ ពុំមានភាពក្រីក្រ, គោលដៅទី២៖ គ្រោះអត់ឃ្លានស្មើសូន្យ, គោលដៅទី៣៖ សុខភាព និងសុខុមាលភាពមាំមួន, គោលដៅទី៤៖ ការអប់រំប្រកបដោយគុណភាព, គោលដៅទី៥៖ សមភាពយេនឌ័រ, គោលដៅទី៨៖ ការងារសមរម្យ និងកំណើនសេដ្ឋកិច្ច និងគោលដៅទី១៧៖ ភាពជាដៃគូដើម្បីសម្រេចគោលដៅ។

គណៈកម្មការដឹកនាំនិងគ្រប់គ្រងការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន សង្ឃឹមថា ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ វិស័យឯកជន និងភាគីពាក់ព័ន្ធ នឹងប្តេជ្ញាចិត្តរួមគ្នាចូលរួមអនុវត្តផែនការសកម្មភាពអនុវត្តគោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀន

នេះប្រកបដោយស្មារតីទទួលខុសត្រូវ ផ្ដល់កិច្ចសហការ គាំទ្រ និងចូលរួមយ៉ាងសកម្មក្នុងគ្រប់ដំណើរការនៃការអនុវត្តផែនការសកម្មភាពប្រកបដោយជោគជ័យ។

ថ្ងៃ សុក្រ ៣កើត ខែ កត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
**និងជាប្រធានគណៈកម្មការដឹកនាំនិងគ្រប់គ្រង**
**ការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**


១.សាវតារ

ការផ្តល់អាហារតាមសាលារៀន ត្រូវបានទទួលស្គាល់ទូទាំងពិភពលោកថាជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយសម្រាប់បង្កើនការទទួលបានសេវាអប់រំ លើកកម្ពស់សុខភាពនិងអាហារូបត្ថម្ភកុមារ កាត់បន្ថយអសន្តិសុខស្បៀង ជំរុញនិងបង្កើនភាពអង់អាចស្ត្រីដែលជាមេគ្រួសារ និងអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានតាមរយៈការទិញកសិផលពីកសិករនិងអ្នកផ្គត់ផ្គង់នៅក្នុងសហគមន៍។

នៅប្រទេសកម្ពុជា ការផ្តល់អាហារតាមសាលារៀន បានរួមចំណែកដោយផ្ទាល់ក្នុងគោលដៅជាតិសម្រាប់ធានាការគ្របដណ្តប់សុខភាពជាសកល តាមរយៈការកែលម្អអាហារូបត្ថម្ភ ការជំរុញឱ្យកុមារលូតលាស់មានសុខភាពល្អ និងការកាត់បន្ថយជំងឺដែលទាក់ទងនឹងបញ្ហាអាហារូបត្ថម្ភ។ ការផ្តល់អាហារដែលមានគុណភាព និងសមរម្យនៅសាលារៀនជារបៀបសំខាន់មួយសម្រាប់ផ្តល់សេវាអាហារូបត្ថម្ភ និងសុខភាពដល់កុមារគ្រប់អាយុចូលរៀន ដែលអាចពង្រឹងដល់វិស័យសុខាភិបាល និងគាំពារសង្គម។ កម្មវិធីនេះមានការអភិវឌ្ឍគួរឱ្យកត់សម្គាល់ក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមកនេះ ដោយផ្តើមពីការឆ្លើយតបបន្ទាន់លើបញ្ហាអសន្តិសុខស្បៀង និងការវិវឌ្ឍបណ្តើរៗទៅជាកម្មវិធីជាតិ ដើម្បីធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃការអប់រំ និងអាហារូបត្ថម្ភរបស់កុមារ។

ការផ្តល់អាហារតាមសាលារៀន ត្រូវបានផ្តួចផ្តើមអនុវត្តដោយកម្មវិធីស្បៀងអាហារពិភពលោកនៅឆ្នាំ១៩៩៩ ដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ផ្តោតលើការផ្តល់អាហារដល់កុមារនៅក្នុងខេត្តដែលមានបញ្ហាអសន្តិសុខស្បៀង និងងាយរងគ្រោះបំផុតដើម្បីជំរុញការចូលរៀន និងកាត់បន្ថយភាពស្រេកឃ្លានរយៈពេលខ្លី។ បន្ទាប់ពីការអនុវត្តការផ្តួចផ្តើមខាងលើបានជោគជ័យ កម្មវិធីស្បៀងអាហារពិភពលោកបានពង្រីកវិសាលភាពជាបន្តបន្ទាប់ដោយបានផ្តល់អត្ថប្រយោជន៍ដល់សាលារៀនរាប់ពាន់ និងកុមាររាប់សែននាក់។

ស្ថិតក្នុងស្ថានភាពសេដ្ឋកិច្ចកម្ពុជាមានភាពល្អប្រសើរ ការផ្លាស់ប្តូរពីការពឹងផ្អែកលើការឧបត្ថម្ភជាស្បៀងពីម្ចាស់ជំនួយ ទៅជាយុទ្ធសាស្ត្រថ្មីមួយប្រកបដោយនិរន្តរភាពត្រូវបានបង្កើតឡើង។ក្នុងឆ្នាំ២០១៤ ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយកម្មវិធីស្បៀងអាហារពិភពលោក បានសាកល្បងកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ ដោយផ្សារភ្ជាប់កម្មវិធីផ្តល់អាហារតាមសាលារៀនទៅនឹងការផលិតស្បៀងក្នុងសហគមន៍មូលដ្ឋាន។ យោងតាមរបាយការណ៍វាយតម្លៃរបស់កម្មវិធីស្បៀង

អាហារពិភពលោក កម្មវិធីផ្តល់អាហារតាមសាលារៀនជំរុញការបង្កើនការចុះឈ្មោះចូលរៀនសិស្សបានខ្ពស់រហូតដល់ ៩៩,៦ភាគរយ ធៀបទៅនឹងសាលារៀនដែលពុំមានកម្មវិធីនេះដែលមានអត្រាចុះឈ្មោះចូលរៀនត្រឹមតែ៩៥,២ភាគរយ ប៉ុណ្ណោះ។ អត្រាបោះបង់ការសិក្សានៅសាលារៀនអនុវត្តកម្មវិធីធ្លាក់ចុះពី១២ភាគរយនៅឆ្នាំសិក្សា២០១៣-២០១៤ មក ៦ភាគរយ នៅឆ្នាំសិក្សា ២០១៥-២០១៦ និងបន្តធ្លាក់ចុះដល់២,៤ភាគរយ នៅឆ្នាំសិក្សា ២០២៣-២០២៤ ស្របពេលដែលអត្រាបោះបង់ការសិក្សានៅថ្នាក់ជាតិមាន៧,៥ភាគរយ។ សាលារៀនដែលអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន មានអត្រាបញ្ចប់ការសិក្សាខ្ពស់ស្ថិតក្នុងអត្រា ៨១,៣ភាគរយ។ អត្រានេះខ្ពស់ជាងសាលារៀនដែលពុំមានកម្មវិធីដែលមានអត្រាបញ្ចប់ការសិក្សាប្រមាណ ៨០,១ភាគរយ មុនពេលមានវិបត្តិកូវីដ-១៩។

កម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ បានផ្តល់អត្ថប្រយោជន៍ផ្នែកគាំពារសង្គមយ៉ាងច្រើន តាមរយៈការកាត់បន្ថយចំណាយលើថ្លៃអាហាររបស់កុមារ ជាពិសេសកុមារដែលមកពីគ្រួសារមានប្រាក់ចំណូលទាប។ ការទទួលបានអាហារមួយពេលនៅសាលារៀន បានជួយកាត់បន្ថយចំណាយប្រហែល ៥ភាគរយ នៃការចំណាយរបស់គ្រួសារលើការទិញអាហារ និងប្រមាណ ២ភាគរយ នៃចំណាយសរុបរបស់គ្រួសារ។ ជាមួយគ្នានេះផងដែរ អាហារមួយពេលដែលបានផ្តល់នៅសាលារៀនអាចជួយកាត់បន្ថយការចំណាយរហូតដល់១០ភាគរយ នៃការចំណាយលើថ្លៃអាហារក្នុងគ្រួសារដែលមានប្រាក់ចំណូលទាប។ ការផ្តល់អាហារតាមសាលារៀន ក៏បានបង្កើតការងារជូនដល់ចុងភៅជាច្រើនកន្លែង ជារៀងរាល់ឆ្នាំចុងភៅតែងទទួលបានប្រាក់ឧបត្ថម្ភសម្រាប់ការងារចម្អិនអាហារនៅតាមសាលារៀន។ ការផ្តល់ប្រាក់ឧបត្ថម្ភដល់ចុងភៅសាលារៀនបានចូលរួមប្រហែល ២៤ភាគរយ នៃចំណាយប្រចាំឆ្នាំរបស់គ្រួសារ ហើយអាចកើនឡើងរហូតដល់ ៥៦ភាគរយ នៃចំណាយប្រចាំឆ្នាំរបស់គ្រួសារដែលមានប្រាក់ចំណូលទាប។ លើសពីនេះកម្មវិធីក៏បានរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ដោយបង្កើនប្រាក់ចំណូលប្រមាណ ៨ភាគរយ ដល់អ្នកផ្គត់ផ្គង់ស្បៀង រួមទាំងកសិករផងដែរ។ ជារួមកម្មវិធីផ្តល់អាហារតាមសាលារៀន ជាយុទ្ធសាស្ត្រមួយដែលមិនត្រឹមតែធានាបានការផ្តល់អាហារូបត្ថម្ភកាន់តែប្រសើរសម្រាប់សិស្សានុសិស្សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនតាមរយៈការកាត់បន្ថយចំណាយលើថ្លៃអាហារ បង្កើនទម្លាប់ដាំដុះដំណាំនៅជុំវិញផ្ទះ

ការចិញ្ចឹមសត្វ និងការចូលរួមរបស់កសិករខ្នាតតូចនិងសហគមន៍កសិកម្មក្នុងសកម្មភាពផ្តល់អាហារតាមសាលារៀន។

ផ្អែកតាមភាពជោគជ័យនេះ រាជរដ្ឋាភិបាលកម្ពុជា បានទទួលយកកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ មកអនុវត្តនៅឆ្នាំ២០១៩ ដោយបានវិភាជថវិកាជាតិ សម្រាប់ការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនចាប់ពីឆ្នាំសិក្សា២០១៩-២០២០ រហូតមកដល់បច្ចុប្បន្ន ដែលបញ្ជាក់ពីដំណើរឆ្ពោះទៅភាពជាម្ចាស់នៃកម្មវិធីផ្តល់អាហារតាមសាលារៀន។ ការផ្តល់អាហារតាមសាលារៀនត្រូវបានអនុវត្តភាពច្រើនក្នុងទម្រង់ជាការផ្តល់អាហារពេលព្រឹក និងនៅតាមសាលាមួយចំនួនតូចអនុវត្តក្នុងទម្រង់ ជាការផ្តល់អាហារថ្ងៃត្រង់ ក្រោមការដឹកនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា និងការគ្រប់គ្រងរបស់គណៈកម្មការដឹកនាំ និងគ្រប់គ្រងចំពោះកិច្ចនៅថ្នាក់ក្រោមជាតិនិងថ្នាក់មូលដ្ឋាន។

នៅឆ្នាំ២០២១ រាជរដ្ឋាភិបាលកម្ពុជា បានចូលជាសមាជិកសម្ព័ន្ធប្រតិបត្តិករសាកលកម្មវិធីផ្តល់អាហារតាមសាលារៀនដែលមានបេសកកម្មជានាថា នៅឆ្នាំ២០៣០ កុមារគ្រប់រូបនឹងទទួលបានអាហារតាមសាលារៀន ដែលអាហារទាំងនោះមានអាហារូបត្ថម្ភ និងមានជីវជាតិជំរុញការលូតលាស់ និងរីកចម្រើនដល់ការសិក្សា។ នៅឆ្នាំ២០២២ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសឆន្ទៈជាសមាជិកសម្ព័ន្ធប្រតិបត្តិករសាកលកម្មវិធីផ្តល់អាហារតាមសាលារៀន ក្នុងការពង្រឹងអាហារូបត្ថម្ភ សុខភាព និងការអប់រំសម្រាប់កុមារ ដែលនេះគឺជាជំហានដ៏សំខាន់មួយ ដែលបង្ហាញពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការពង្រឹងនិងពង្រីកកម្មវិធីផ្តល់អាហារតាមសាលារៀននៅកម្ពុជា ប្រកបដោយនិរន្តរភាពនិង បរិយាបន្ន។ នៅឆ្នាំ២០២៣ រាជរដ្ឋាភិបាលកម្ពុជាបានចូលរួមក្នុងកិច្ចប្រជុំកំពូលរបស់សម្ព័ន្ធប្រតិបត្តិករសាកលកម្មវិធីផ្តល់អាហារតាមសាលារៀន រៀបចំឡើងនៅទីក្រុងប៉ារីស សាធារណរដ្ឋបារាំងដែលជាការជួបជុំមេដឹកនាំរដ្ឋ និងរដ្ឋាភិបាលជាសមាជិក ក៏ដូចជាដៃគូពាក់ព័ន្ធដែលមានការយល់ព្រមធ្វើការរួមគ្នាក្រោមទិសដៅ និងបេសកម្មតែមួយគឺដើម្បីបង្កើនគុណភាព នីរន្តរភាព និងពង្រីកកម្មវិធីផ្តល់អាហារតាមសាលារៀន និងបំពេញបន្ថែមការអន្តរាគមន៍ផ្សេងៗ។ នៅឆ្នាំ២០២៥ រាជរដ្ឋាភិបាលកម្ពុជា បានចូលរួមក្នុងកិច្ចប្រជុំកំពូលលើកទី២ សម្ព័ន្ធប្រតិបត្តិករសាកលកម្មវិធីផ្តល់អាហារតាមសាលារៀន នៅប្រទេសប្រេស៊ីល។ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាលើកកម្ពស់គុណភាព អាហារូបត្ថម្ភនៃកម្មវិធីផ្តល់អាហារតាមសាលារៀន

ដោយប្រើប្រាស់កសិផលក្នុងសហគមន៍ រួមទាំងការបញ្ចូលមីក្រូសារជាតិទៅក្នុងអាហារ ដូចបញ្ជាក់ក្នុងការប្តេជ្ញាចិត្តនៃការកែលម្អអាហារូបត្ថម្ភសម្រាប់ការលូតលាស់ (N4G) នៅឆ្នាំ២០២៥ ផងដែរ។

ផ្អែកតាមយុទ្ធសាស្ត្ររួមផ្ទេរ-ទទួលផ្ទេរទៅកម្មវិធីជាតិផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ដំណាក់កាលទី១(២០២២-២០២៥) ដែលបានអនុម័តនៅឆ្នាំ២០២២ រាជរដ្ឋាភិបាលកម្ពុជា មានឆន្ទៈទទួលយកសាលារៀនគោលដៅលើសពី១០០ រាល់ឆ្នាំពីកម្មវិធីស្បៀងអាហារពិភពលោករហូតដល់ឆ្នាំ២០២៨ ដោយបន្តពង្រីកគោលដៅនិងបង្កើនថវិកាជាលំដាប់មកលើការអនុវត្តកម្មវិធី។

ក្នុងឆ្នាំសិក្សា២០២៤-២០២៥ នេះមានសាលាបឋមសិក្សាគោលដៅ ១,១១៤ (សិស្សសរុប ៣០៧,៥៥៩ នាក់ សិស្សស្រី ៤៨,៧ ភាគរយ) បាននិងកំពុងអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ ក្នុងនោះសាលាបឋមសិក្សា ៦៨៦ (សិស្សសរុប ១៨៩,៥៩៣ នាក់ សិស្សស្រី ៤៨,៦ ភាគរយ) កំពុងអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនប្រើប្រាស់ថវិការដ្ឋ រីឯសាលាបឋមសិក្សា ៤២៨ ផ្សេងទៀត (សិស្សសរុប ១១៧,៩៦៦ នាក់ សិស្សស្រី ៤៨,៩ ភាគរយ) កំពុងអនុវត្តកម្មវិធីផ្តល់អាហារដោយប្រើប្រាស់ធនធានដែលគាំទ្រពីកម្មវិធីស្បៀងអាហារពិភពលោក។ សាលារៀនដែលនៅសេសសល់នឹងផ្ទេរមកអនុវត្តជាកម្មវិធីជាតិទាំងស្រុងនៅត្រឹមឆ្នាំ២០២៨។

គោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀន ឆ្នាំ២០២៤-២០៣៥ ត្រូវបានដាក់ឱ្យប្រើប្រាស់នៅឆ្នាំ២០២៤ ដែលជាទឡ្ហីករណ៍មួយនៃក្របខ័ណ្ឌច្បាប់ ដើម្បីឱ្យក្រសួង ស្ថាប័ន មានឱកាសសិក្សារៀនសូត្រពីលទ្ធភាពនៃការពង្រីកកម្មវិធីដោយបញ្ជាក់អំពីយុទ្ធសាស្ត្រនិរន្តរភាពហិរញ្ញវត្ថុ និងប្រសិទ្ធភាពប្រតិបត្តិការ។ លើសពីនេះ កម្មវិធីផ្តល់អាហារតាមសាលារៀនអនុវត្តទៅដោយអនុលោមតាម ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០២៤-២០២៨, ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥ យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភលើកទី៣ ឆ្នាំ២០២៤-២០២៨ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០២៤-២០២៨ ដែលផ្តល់អាទិភាពដល់ការអប់រំប្រកបដោយសមធម៌ គុណភាព និងបរិយាបន្ន ព្រមទាំងការដាក់កម្មវិធីផ្តល់អាហារតាមសាលារៀនជាសំណាញ់សុវត្ថិភាពសង្គមដ៏សំខាន់សម្រាប់កាត់បន្ថយភាពក្រីក្រ អសន្តិសុខស្បៀង និងការអភិវឌ្ឍមូលធនមនុស្ស។

បើទោះបីជាមានសមិទ្ធផលសម្រេចបានជាច្រើនយ៉ាងណាក៏ដោយ ក៏បញ្ហាប្រឈមនៅតែកើតមានក្នុងការធានានិរន្តរភាពហិរញ្ញវត្ថុនៃកម្មវិធី ការកែលម្អគុណភាពអាហារ និងស្តង់ដាសុវត្ថិភាពម្ហូបអាហារ ប្រសិទ្ធភាពខ្សែច្រវាក់ផ្គត់ផ្គង់ និងការចូលរួមរបស់កសិករផលិតស្បៀងតម្រូវការហេដ្ឋារចនាសម្ព័ន្ធ ការពង្រឹងសមត្ថភាពស្ថាប័ន និងការសម្របសម្រួលក្នុងចំណោមភាគីពាក់ព័ន្ធសំខាន់ៗ។ បញ្ហាប្រឈមទាំងនេះបង្ហាញពីភាពចាំបាច់នៃការរៀបចំផែនការសកម្មភាពអនុវត្តគោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀន ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយសម្រាប់អនុវត្តក្នុងឆ្នាំ២០២៤-២០៣៥ និងដើម្បីធានាការអនុវត្តគោលនយោបាយប្រកបដោយប្រសិទ្ធភាព និងការផ្តល់អាហារតាមសាលារៀនមានចីរភាពភាព បរិយាបន្ន និងប្រកបដោយកម្មវិបាកធំធេង។

ផែនការសកម្មភាពអនុវត្តគោលនយោបាយស្តីពី ការផ្តល់អាហារតាមសាលារៀន ដំណាក់កាលទី១(២០២៤-២០៣០) ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ជាពិសេសទាក់ទងនឹងការអប់រំអាហារូបត្ថម្ភ និងការលុបបំបាត់ភាពក្រីក្រ ដោយបន្សុំទៅនឹងអាទិភាពនានានៃកម្មវិធីអភិវឌ្ឍផ្សេងទៀតផងដែរ។

ផែនការសកម្មភាពអនុវត្តគោលនយោបាយនេះ នឹងបង្ហាញផ្លូវដាក់លាក់សម្រាប់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ និងវិស័យពាក់ព័ន្ធក្នុងការសហការយ៉ាងមានប្រសិទ្ធភាព ដើម្បីធានាថា សិស្សានុសិស្ស ជាពិសេសកុមារដែលកំពុងស្ថិតក្រោមស្ថានភាពងាយរងគ្រោះ និងអសន្តិសុខស្បៀង បានទទួលអាហារតាមសាលារៀនទៀងទាត់ ប្រកបដោយគុណភាព និងសុវត្ថិភាព។ លើសពីនេះ ផែនការសកម្មភាពនេះ មិនត្រឹមតែជាក្របខ័ណ្ឌសម្រាប់ការសម្រេចចក្ខុវិស័យគោលនយោបាយប៉ុណ្ណោះទេ ប៉ុន្តែវាក៏បង្ហាញពីឆន្ទៈដ៏មោះមុតរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកកម្ពស់សមត្ថភាពអ្នកជំនាន់ក្រោយ ដោយផ្តល់ការវិនិយោគលើអាហារតាមសាលារៀន ដើម្បីបំបែកវដ្តនៃភាពក្រីក្រ លើកស្ទួយការអភិវឌ្ឍធនធានមនុស្ស និងកសាងសហគមន៍ឱ្យមានភាពធន់ និងរឹងមាំ។

## ១.១. គោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀន

**១.១.១. ចក្ខុវិស័យ**

រួមចំណែកអភិវឌ្ឍមូលធនមនុស្សដោយបំពាក់នូវវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទាពេញលេញ សំដៅរួមចំណែកកសាងសង្គមកម្ពុជាឱ្យមានការអភិវឌ្ឍប្រកបដោយវិបុលភាព។

**១.១.២. គោលបំណង**

ផ្តល់អាហារប្រកបដោយសុវត្ថិភាព និងអាហារូបត្ថម្ភដល់សិស្ស ដើម្បីជំរុញការលូតលាស់ និងភាពវៃឆ្លាត សំដៅលើកកម្ពស់ផលិតភាពការងារ សមភាពយេនឌ័រ និងបរិយាបន្ន ដោយមានវិសាលភាពចាប់ពីកម្រិតមត្តេយ្យសិក្សារហូតដល់មធ្យមសិក្សាសាធារណៈនាពេលអនាគត។

## ១.២. ស្ថានភាព

ប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចយ៉ាងលឿនក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះជាមួយនឹងកំណើនសេដ្ឋកិច្ចជាមធ្យមជាង ៧ ភាគរយ ក្នុងមួយឆ្នាំ មុនពេលមានវិបត្តិនៃជំងឺកូវីដ-១៩ និងបានប្រែក្លាយពីប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៥ និងត្រៀមចាកចេញពីប្រទេសអភិវឌ្ឍន៍តិចតួចឆ្ពោះទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០[1]។

ទោះបីជាយ៉ាងណាក៏ដោយ ជំងឺរាតត្បាតកូវីដ-១៩ បានធ្វើឱ្យកំណើនសេដ្ឋកិច្ចកម្ពុជាថយចុះប្រមាណ ៣,១ភាគរយ នៅឆ្នាំ២០២០ មុនពេលងើបឡើងវិញ ដែលមានកំណើន ៥,៨ភាគរយ នៅឆ្នាំ២០២៤។ ក្រោយវិបត្តិកូវីដ-១៩ អតិផរណាឡើង ដល់ ៧,៨ភាគរយនៅឆ្នាំ២០២២ ជាអត្រាខ្ពស់បំផុតក្នុងរយៈពេល ១៣ឆ្នាំ ដែលមួយភាគធំដោយសារការកើនឡើងថ្លៃស្បៀងអាហារ និងផលិតផលប្រេងឥន្ធនៈ បណ្តាលមកពីជម្លោះរុស្ស៊ី និង



[1] យុទ្ធសាស្ត្រគ្រប់គ្រងចំណូលសាធារណៈ ២០២៤-២០២៨

អ៊ុយក្រែន ជាហេតុធ្វើឱ្យផែនការកាត់បន្ថយភាពក្រីក្រ មានភាពយឺតយ៉ាវ ដោយសារចំណូលរបស់គ្រួសារត្រូវបានថយចុះ។ ការប្រែប្រួលសេដ្ឋកិច្ច បានជះឥទ្ធិពលដោយផ្ទាល់លើការចំណាយទិញស្បៀង សម្រាប់កម្មវិធីផ្តល់អាហារតាមសាលារៀនជាពិសេសអាហារមានជីវជាតិដល់សិស្ស ព្រោះស្បៀងទាំងនោះមានតម្លៃខ្ពស់។

ប្រជាជនក្រីក្រនៅប្រទេសកម្ពុជាបានបន្តរស់នៅក្រោមបន្ទាត់ភាពក្រីក្រ ដោយជួបបញ្ហាប្រឈមក្នុងការផ្តល់អាហារូបត្ថម្ភសម្រាប់កូនៗរបស់ពួកគេ។ ជាក់ស្តែងនៅឆ្នាំ២០២០ ប្រជាជនក្រីក្រប្រមាណ ១៧,៨ភាគរយ រស់នៅក្រោមបន្ទាត់ភាពក្រីក្រ ដែលក្នុងនោះមាន ២២,៨ភាគរយ ជាប្រជាជនរស់នៅតំបន់ជនបទ និង១២,៦ភាគរយ រស់នៅទីក្រុងនិងទីប្រជុំជន[2]។

លើសពីនេះ ប្រជាជនកម្ពុជាក៏ងាយរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុផងដែរ ដែលអាចបង្កការគំរាមកំហែងដល់ជីវភាពរបស់គ្រួសារនៅជនបទ និងគ្រួសារដែលគ្មានដីសម្រាប់ប្រកបរបរកសិកម្ម ដោយបង្អាក់ផលិតកម្មកសិកម្ម ការប្រើប្រាស់ទឹក និងការដឹកកសិផល។ ដូច្នេះ ការវិនិយោគលើកម្មវិធីផ្តល់អាហារតាមសាលារៀនកាន់តែមានសារៈសំខាន់ដោយបានផ្តល់ការងារដល់គ្រួសារក្រីក្រដែលប្រកបរបរកសិកម្ម និងរួមចំណែកកាត់បន្ថយគម្លាតនៃភាពក្រីក្ររវាងប្រជាជនរស់នៅតាមតំបន់ភូមិសាស្ត្រងាយរងគ្រោះ និងនៅតាមទីក្រុង។ ការផ្តល់អាហារតាមសាលារៀន អាចជួយបំពេញតម្រូវការអាហារូបត្ថម្ភប្រមាណ៤០ភាគរយ នៃតម្រូវប្រចាំថ្ងៃរបស់រាងកាយ ធានាថាសិស្សមានសុខភាពល្អ អាចផ្តោតការយកចិត្តទុកដាក់លើការរៀនសូត្រ[3] ហើយការផ្តល់អាហារតាមសាលារៀនបានក្លាយទៅជាអន្តរាគមន៍ដ៏សំខាន់ដើម្បីធានាសន្តិសុខស្បៀងនិងទប់ស្កាត់កង្វះអាហារូបត្ថម្ភ។

ការអប់រំនៅតែជាឧបសគ្គចម្បងមួយក្នុងទសវត្សរ៍ចុងក្រោយនេះ បើទោះបីជាកម្ពុជាបានបង្កើនអត្រាពិតនៃការសិក្សានៅកម្រិតបឋមសិក្សាពី៩១,០ភាគរយ នៅឆ្នាំសិក្សា ២០១៩-២០២០[4] ដល់ ៩៣,១ភាគរយ នៅឆ្នាំសិក្សា២០២៤-២០២៥[5] ដល់កម្រិតប្រហាក់ប្រហែលនឹងប្រទេសដែលមានចំណូលខ្ពស់ ប៉ុន្តែអត្រាពិតនៃការសិក្សានៅកម្រិត

[2] ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា ឆ្នាំ២០២០

[3] របាយការណ៍កម្មវិធីស្បៀងអាហារពិភពលោក ឆ្នាំ២០២៣

[4] ស្ថិតិ និងសូចនាករអប់រំសាធារណៈឆ្នាំសិក្សា២០១៩-២០២០

[5] ស្ថិតិ និងសូចនាករអប់រំសាធារណៈឆ្នាំសិក្សា២០២៤-២០២៥

មធ្យមសិក្សាបឋមភូមិមានការកើនឡើងតិចតួចពី៤៥,៧ នៅឆ្នាំសិក្សា២០១៩-២០២០[6] ដល់ ៥៧,៤ភាគរយ ក្នុងឆ្នាំសិក្សា២០២៤-២០២៥[7] ដែលនៅតែទាបជាងប្រទេសអាស៊ាន ដទៃទៀត។ កម្ពុជាមានពិន្ទុមូលធនមនុស្សដែលវាស់វែងដោយសន្ទស្សន៍មូលធនមនុស្ស របស់ធនាគារពិភពលោក (HCI) ទាបជាងប្រទេសដែលមានស្ថានភាពប្រហាក់ប្រហែលគ្នា។ សន្ទស្សន៍មូលធនមនុស្សរបស់កម្ពុជាមាន ០,៤៩[8] បង្ហាញពីភាពខ្វះខាតនៃអាហារូបត្ថម្ភ សម្រាប់កុមារតូច និងចំណុចខ្វះចន្លោះក្នុងប្រព័ន្ធអប់រំ ដោយមានអត្រាក្រិសក្រិនខ្ពស់ ការចុះឈ្មោះចូលរៀនយឺត អត្រាត្រួតថ្នាក់ខ្ពស់ និងអត្រាបោះបង់ការសិក្សាខ្ពស់។

វិសមភាពយេនឌ័រក្នុងវិស័យអប់រំ និងកង្វះអាហារូបត្ថម្ភនៅតែកើតមាន បើទោះជាប្រទេសកម្ពុជាមានការរីកចម្រើនក្នុងការលើកកម្ពស់សិទ្ធិទទួលបានការអប់រំក៏ដោយ។ កុមារី និងក្មេងស្រីដែលរស់នៅតាមតំបន់ជនបទទំនងជាបោះបង់ការសិក្សាដោយសារកត្តាសេដ្ឋកិច្ច ការធាប់រៀបការ និងការទទួលខុសខ្ពស់ត្រូវក្នុងគ្រួសារ។ អត្រាចុះឈ្មោះចូលរៀនរបស់ក្មេងស្រីនៅបឋមសិក្សាមាន ៩៤,៣ភាគរយ ប៉ុន្តែតួលេខនេះមានការធ្លាក់ចុះខ្លាំងនៅកម្រិតមធ្យមសិក្សា ដែលមានតែ ៦០ភាគរយ នៃក្មេងស្រីបានបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិ។

កង្វះអាហារូបត្ថម្ភ នៅតែជាបញ្ហាសុខភាពសាធារណៈដ៏សំខាន់នៅក្នុងប្រទេសកម្ពុជា ជាពិសេសកុមារ និងមនុស្សវ័យជំទង់ដែលរស់នៅក្នុងតំបន់ជួបការលំបាក និងក្រុមងាយរងគ្រោះ។ យោងតាមទិន្នន័យចុងក្រោយបានបង្ហាញថា បញ្ហាកង្វះអាហារូបត្ថម្ភបានថយចុះ ប៉ុន្តែបញ្ហាលើសអាហារូបត្ថម្ភ និងជំងឺមិនឆ្លងកំពុងតែមានការកើនឡើង។ បញ្ហាទាំងនេះបានបន្តប៉ះពាល់ខ្លាំងដល់កុមារនៅអនុវិទ្យាល័យ និងវិទ្យាល័យទូទាំងប្រទេស។ យោងតាមការស្ទង់មតិប្រជាសាស្ត្រនិងសុខភាពសាធារណៈកម្ពុជាឆ្នាំ២០២១-២០២២ បង្ហាញថា កុមារជនបទដែលមានអាយុក្រោម ៥ឆ្នាំ ប្រមាណ២២ ភាគរយ ទទួលរងការក្រិសក្រិនដោយសារកង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃ។ តួលេខនេះមានការធ្លាក់ចុះបើប្រៀបទៅនឹង



[6] ស្ថិតិ និងសូចនាករអប់រំសាធារណៈឆ្នាំសិក្សា២០១៩-២០២០

[7] ស្ថិតិ និងសូចនាករអប់រំសាធារណៈឆ្នាំសិក្សា២០២៤-២០២៥

[8] ការវាយតម្លៃភាពក្រីក្រនៅប្រទេសកម្ពុជាឆ្នាំ២០២២

អត្រាក្រិសក្រិននៅឆ្នាំ២០១៤ ដែលមានអត្រា ៣២ភាគរយ[9]។ កុមារអាយុក្រោម៥ឆ្នាំ ប្រមាណ១០ ភាគរយ មានរូបរាងស្គមស្គាំង និង ៤ ភាគរយ លើសទម្ងន់ ហើយ ១៤ភាគរយ នៃស្ត្រីអាយុចាប់ពី១៥-១៩ឆ្នាំមានកម្ពស់ទាប ២៩ភាគរយ មានរាងកាយស្គមស្គាំង និង ៦ភាគរយ លើសទម្ងន់[10]។ ទោះបីជាការស្ទង់មតិផ្តោតជាចម្បងលើកុមារតូចៗ(អាយុក្រោម ៥ឆ្នាំ) ក៏ដោយ ក៏ផលប៉ះពាល់នៃភាពក្រិសក្រិនទៅលើកុមារទាំងនោះនឹងបន្តដល់វ័យ ជំទង់ដែលជាសិស្សនៅអនុវិទ្យាល័យនិងវិទ្យាល័យ។ យោងតាមរបាយការណ៍របស់ អង្គការសុខភាពពិភពលោកឆ្នាំ២០២២ កុមារកម្ពុជាប្រមាណ ១៧ភាគរយ មានអាយុចាប់ ពី៥ឆ្នាំ ដល់៩ឆ្នាំ មានបញ្ហាលើសទម្ងន់ និង ៧ភាគរយ មានរាងកាយស្គមស្គាំង[11]។ លទ្ធផល ដ៏គួរឱ្យភ្ញាក់ផ្អើលនេះបានបង្ហាញថា ខណៈពេលដែលមិនមានការប្រែប្រួលប្រេវ៉ាឡង់នៃ ភាពស្គមស្គាំងក្នុងចំណោមកុមារវ័យបឋមសិក្សា ចន្លោះឆ្នាំ ២០១០ និង ២០២២ ក៏ដោយ ប្រេវ៉ាឡង់នៃការលើសទម្ងន់ឬធាត់កើនឡើងជិតពីរដងពី ១០ ភាគរយ ដល់ ១៧ ភាគរយ ក្នុងឆ្នាំ២០២២ គិតចាប់ពីឆ្នាំ ២០១០ មក។ ការទទួលទានអាហារសម្រន់និងភេសជ្ជៈ ដែល មានខ្លាញ់ អំបិល និងស្ករខ្ពស់ បានគម្រាមកំហែងដល់សុខភាពរបស់កុមារ។ នៅឆ្នាំ២០២៣ តាមរយៈរបាយការណ៍វាយតម្លៃស្តង់ដាអាហារូបត្ថម្ភ នៃកម្មវិធីផ្តល់អាហារតាមសាលារៀន កុមារប្រមាណ ៨៧ភាគរយ បានទទួលទានអាហារ ឬភេសជ្ជៈដែលមិនល្អចំពោះសុខភាព កុមារកាលពីថ្ងៃម្សិល[12] ហើយ ៣៦ភាគរយនៃបរិមាណកាឡូរីនៃតម្រូវការប្រចាំថ្ងៃរបស់ កុមារបានមកពីការទទួលទានអាហារសម្រន់ឬភេសជ្ជៈដែលមិនល្អទាំងនោះ[13] ។

ទម្លាប់នៃការបរិភោគអាហារនៅកម្ពុជា ចាក់ឫសយ៉ាងជ្រៅតាមប្រពៃណី វប្បធម៌ ដោយការយកបាយជាអាហារគោល។ ទោះបីជាយ៉ាងណាក៏ដោយ ការប្រើប្រាស់ ប្រូតេអ៊ីន ផ្លែឈើនិងបន្លែតិចបណ្តាលឱ្យមានកង្វះមីក្រូសារជាតិក្នុងបរិមាណយ៉ាងច្រើន[14]។ គេក៏



---

9 យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភលើកទី៣ ឆ្នាំ២០២៤-២០២៨

10 ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ២០២១-២០២២

11 របាយការណ៍អង្គការសុខភាពពិភពលោកឆ្នាំ ២០២៥ ស្តីពីការអង្កេតសុខភាពជាសកល

12 របាយការណ៍ស្តីពីការហូបអាហាររបស់កុមាររបស់ ក្រសួងអប់រំ យុវជននិងកីឡា អង្គការហេលេនខេលើរ កម្មវិធីស្បៀងអាហារពិភពលោក និងអង្គការស្បៀង និងកសិកម្ម ឆ្នាំ២០២៣

13 របាយការណ៍វាយតម្លៃទិន្នន័យដើមស្តីពីស្តង់ដាអាហារូបត្ថម្ភនៃកម្មវិធីផ្តល់អាហារតាមសាលារៀន ឆ្នាំ២០២៣

14 របាយការណ៍សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ របស់អង្គការស្បៀងនិងកសិកម្មនៃអង្គការសហប្រជាជាតិ ឆ្នាំ២០២៣

សង្កេតឃើញផងដែរថា កុមារក្នុងវ័យនៅតាមជនបទ និងតំបន់ដាច់ស្រយាល តែងបរិភោគអាហារខ្វះភាពចម្រុះ ដោយការហូបបាយក្នុងបរិមាណដ៏ច្រើន រួមទាំងអាហារមានប្រូតេអ៊ីន និងមីក្រូសារជាតិចិញ្ចឹមតិចតួច។ ប្រជាជនប្រមាណជិត ៣០ ភាគរយ មិនបានបរិភោគបន្លែ និងផ្លែឈើទាល់តែសោះក្នុងរយៈពេល៦-២៣ ខែកន្លងមក[15]។

ការទទួលបានអាហារដែលគ្មានភាពចម្រុះ អាចបណ្ដាលឱ្យមានផលប៉ះពាល់ដល់លទ្ធផលនៃការសិក្សារបស់សិស្ស។ របាយការណ៍វង្វាយតម្លៃការសិក្សាអន្តរជាតិសិស្សអាយុ១៥ឆ្នាំនៅកម្ពុជា ឆ្នាំ២០១៨ បានបង្ហាញថា លទ្ធផលនៃការសិក្សារបស់សិស្សនៅជនបទ និងទីក្រុងមានគម្លាតប្រមាណកន្លះឆ្នាំ ដែលមានន័យថា សិស្សនៅជនបទមានលទ្ធផលទាបជាងសិស្សនៅទីប្រជុំជន។ លទ្ធផលសិក្សារបស់សិស្សនៅគ្រឹះស្ថានសិក្សាសាធារណៈនិងឯកជនមានគម្លាតប្រមាណ ១,៥ឆ្នាំ[16]។ បើទោះបីជាមិនទាន់មានភស្តុតាងគ្រប់គ្រាន់នៃការបរិភោគអាហារ តែវាអាចបង្ហាញថាការទទួលបានអាហារគ្រប់គ្រាន់មានទំនាក់ទំនងទៅនឹងលទ្ធផលនៃការសិក្សា។

ការផ្ដល់អាហារតាមសាលារៀន ជាពិសេសអាហារដែលមានជីវជាតិសំខាន់ៗ អាចជួយកែលម្អសុខភាពកុមារី បង្កើនអត្រាមករៀន និងទទួលបានការអប់រំក្នុងរយៈពេលវែង។ កម្មវិធីនេះបានដើរតួនាទីសំខាន់ក្នុងការឆ្លើយតបកង្វះអាហារូបត្ថម្ភជាច្រើន ដោយការផ្ដល់អាហារចម្អិនពីអង្ករបញ្ចូលមីក្រូសារជាតិ គ្រាប់ធញ្ញជាតិ បន្លែ ត្រី សាច់ ស៊ុត និងអំបិលអ៊ីយ៉ូដ អាចធានាថាសិស្សនឹងទទួលបានសារជាតុចិញ្ចឹមចាំបាច់ សម្រាប់ការលូតលាស់ទាំងផ្នែកបញ្ញា ស្មារតី និងរាងកាយ[17] ។ កម្មវិធីលើកទឹកចិត្តឱ្យសហគមន៍ និងវិស័យឯកជនចូលរួមផ្ដល់អាហារបន្ថែម ដូចជាផ្លែឈើ គ្រឿងទេស ផលិតផលពីទឹកដោះគោ ទឹកសណ្ដែក រួមទាំងទឹកត្រី និងទឹកស៊ីអ៊ីវ ជូនដល់សាលារៀនក្នុងការអនុវត្តកម្មវិធី។

ការព្រួយបារម្ភអំពីសុវត្ថិភាពចំណីអាហារនៅតែបន្តកើតមាន ជាពិសេសនៅតំបន់ជនបទដែលការគ្រប់គ្រងចំណីអាហារមិនទាន់បានគ្រប់គ្រងត្រឹមត្រូវ។ ចំណុចដែលរាជរដ្ឋាភិបាលកម្ពុជា ផ្ដោតការយកចិត្តទុកដាក់ក្នុងការផ្ដល់អាហារតាមសាលារៀនដោយ



[15] យុទ្ធសាស្ត្រជាតិស្ដីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភលើកទី៣ ឆ្នាំ២០២៤-២០២៨

[16] ការអប់រំនៅកម្ពុជាៈលទ្ធផលពីការចូលរួមរបស់ប្រទេសកម្ពុជា ក្នុងកម្មវិធីអន្តរជាតិស្ដីពីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ឆ្នាំ ២០១៨

[17] របាយការណ៍របស់អង្គការស្បៀងនិងកសិកម្មនៃអង្គការសហប្រជាជាតិ ឆ្នាំ២០២៣

ប្រើប្រាស់កសិផលក្នុងសហគមន៍ នោះគឺការដាក់បញ្ចូលអាហារដែលមានប្រភពក្នុងស្រុក និងចម្រុះទៅក្នុងរបបអាហារតាមសាលារៀន ស្របពេលដែលការជួយដល់កសិករខ្នាតតូច សហគមន៍កសិកម្ម និងការកែលម្អស្តង់ដាម្ហូបអាហារ[18]។ ការចូលរួមរបស់សហគមន៍ក្នុងការអនុវត្តកម្មវិធីមានសារៈសំខាន់ណាស់ចំពោះភាពជោគជ័យនៃការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន ប៉ុន្តែកម្រិតនៃការយល់ដឹងរបស់មាតាបិតា និងការចូលរួមនៅតែមានកម្រិតទាបនៅតាមតំបន់មួយចំនួន។ ការលើកទឹកចិត្តឱ្យមានការចូលរួមរបស់សហគមន៍ក្នុងគំនិតផ្តួចផ្តើមសម្រាប់ការផ្តល់អាហារតាមសាលារៀន អាចជួយបង្កើននិរន្តរភាពកម្មវិធី និងពង្រឹងប្រព័ន្ធស្បៀងក្នុងស្រុក[19]។

កសិកម្មជាមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចកម្ពុជា និងរួមចំណែកប្រមាណ ២២ ភាគរយនៃផលិតផលក្នុងស្រុកសរុប (Gross Domestic Product – GDP) នៅឆ្នាំ២០២២។ ទោះបីជាយ៉ាងនេះ ក៏ដោយវិស័យកសិកម្មប្រឈមនឹងបញ្ហាជាច្រើនដែលជះឥទ្ធិពលដល់ប្រព័ន្ធស្បៀងអាហារកាន់តែស្មុគស្មាញ[20]។ កសិករកម្ពុជាជួបប្រទះបញ្ហាប្រឈម ដូចជា កង្វះទីផ្សារ និងហានិភ័យនៃការធ្លាក់ថ្លៃកសិផលនៅក្នុងរដូវប្រមូលផល កង្វះបច្ចេកទេសកសិកម្មនៅតាមមូលដ្ឋានដែលនាំឱ្យការដាំដុះទទួលបានផលតិចតួច កង្វះដើមទុន និងប្រាក់បង្វិលដើម្បីកែច្នៃផលិតផលកសិកម្ម ហានិភ័យនៃបម្រែបម្រួលអាកាសធាតុ និងបញ្ហាថ្លៃដើមផលិតកម្មខ្ពស់ជាដើម។

រាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់បញ្ហាប្រឈមទាំងនេះ និងបានដាក់ចេញកម្មវិធីគោលនយោបាយអាទិភាពទី៥ និងទី៦ ស្តីពីការលើកស្ទួយផលិតកម្មកសិកម្ម រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផល តាមរយៈកម្មវិធីហិរញ្ញប្បទាន ការដាក់ពង្រាយមន្ត្រីកសិកម្មឃុំ-សង្កាត់ និងការអភិវឌ្ឍសហគមន៍កសិកម្មទំនើប[21]។ លើសពីនេះទៀតរាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងអនុវត្តគំនិតផ្តួចផ្តើមដើម្បីលើកកម្ពស់ប្រព័ន្ធស្បៀង តាមរយៈការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ មានគោលបំណងផ្តល់អាហារមានជីវជាតិដល់សិស្ស ខណៈជួយដល់កសិករក្នុងស្រុកមិនត្រឹមតែដោះស្រាយ



---

[18] ផែនការយុទ្ធសាស្ត្ររបស់កម្មវិធីស្បៀងអាហារពិភពលោកប្រចាំកម្ពុជា ឆ្នាំ២០២៣

[19] របាយការណ៍របស់ក្រុមប្រឹក្សាគាំពារសង្គម ឆ្នាំ២០២៣

[20] របាយការក្រុមប្រឹក្សាជាតិគាំពារសង្គមឆ្នាំ២០២៣

[21] កម្មវិធីគោលនយោបាយអាទិភាពសម្រាប់វិស័យកសិកម្ម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ឆ្នាំ២០២៣

តម្រូវការអាហារូបត្ថម្ភភ្លាមៗប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជំរុញផលិតកម្មកសិកម្មក្នុងស្រុកឱ្យបានកាន់តែប្រសើរ។

រាជរដ្ឋាភិបាលកម្ពុជា បានកំណត់អាទិភាពកម្មវិធីផ្តល់អាហារតាមសាលារៀនជាផ្នែកមួយក្នុងរបៀបវារៈនៃការអភិវឌ្ឍជាតិ តាមរយៈការដាក់បញ្ចូលកម្មវិធីនេះក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០២៤-២០២៨ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០២៤-២០៣៥ យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភលើកទី៣ ឆ្នាំ២០២៤-២០២៨ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០២៤-២០២៨ ដោយទទួលស្គាល់ថាការផ្តល់អាហារតាមសាលារៀន គឺជាកម្មវិធីជួយអន្តរាគមន៍ដ៏សំខាន់មួយសម្រាប់ការកែលម្អលទ្ធផលការសិក្សា សុខុមាលភាពកុមារ សន្តិសុខស្បៀង អាហារូបត្ថម្ភ និងអាហារបញ្ចូលមីក្រូសារជាតិ[22]។ រាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាទទួលយកជាបណ្តើរៗកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ ដោយមានក្រសួងអប់រំ យុវជននិងកីឡា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាស្ថាប័នដើរតួនាទីយ៉ាងសំខាន់ក្នុងការចាត់ចែងរៀបចំនិងវិភាជថវិកាដល់ការអនុវត្តកម្មវិធី ក្រោមកិច្ចសម្របសម្រួលរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម។ ឆ្នាំ២០២៥ នេះរាជរដ្ឋាភិបាលកម្ពុជាផ្តល់ថវិកា ៧,៤ លានដុល្លារ សម្រាប់ការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ជូនសាលារៀន៦៨៦[23]។ អាទិភាពនៃការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន ផ្តោតលើតំបន់ដែលមានអសន្តិសុខស្បៀង ការទទួលបានការអប់រំទាប និងតំបន់ងាយរងគ្រោះ។

ទោះបីជា យុទ្ធសាស្ត្ររួមស្តីពីការផ្ទេរ-ទទួលកម្មវិធីផ្តល់អាហារតាសមសាលារៀនបានអនុវត្តតាមផែនការកំណត់ក៏ដោយ ក៏បញ្ហាប្រឈមជាច្រើននៅតែកើតមានក្នុងការបង្កើនថវិកាសម្រាប់កម្មវិធីផ្តល់អាហារតាមសាលារៀន។ ឧបសគ្គផ្នែកហិរញ្ញវត្ថុនេះបានបង្កជាបញ្ហាប្រឈម ដោយសារការវិភាជថវិការបស់រាជរដ្ឋាភិបាលមានការកើនឡើងរៀងរាល់ឆ្នាំសម្រាប់ការពង្រីកគោលដៅសាលារៀន ការបង្កើនថវិកាសម្រាប់របបអាហារសិស្ស និងប្រាក់ឧបត្ថម្ភចុងភៅ ដោយឡែកថវិកាពង្រឹងសមត្ថភាព ការពិនិត្យតាមដាននិងវាយតម្លៃ



[22] របាយការណ៍ក្រសួងអប់រំ យុវជន និងកីឡាឆ្នាំ២០២៤ និងរបាយការណ៍របស់ក្រុមប្រឹក្សាជាតិគាំពារសង្គម ឆ្នាំ២០២៣
[23] របាយការណ៍អនុម័តថវិការបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម ឆ្នាំ២០២៤

នៅតែត្រូវការការគាំទ្រពីដៃគូអភិវឌ្ឍដូចជា ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ កម្មវិធីស្បៀងអាហារពិភពលោក អង្គការសហប្រជាជាតិ ក្រសួងកសិកម្មសហរដ្ឋអាមេរិក អង្គការជាតិនិងអន្តរជាតិ និងវិស័យឯកជនផងដែរ។ កម្មវិធីផ្តល់អាហារតាមសាលារៀន បច្ចុប្បន្នគ្របដណ្តប់ត្រឹមតែប្រមាណ ១៥ ភាគរយ នៃសាលាបឋមសិក្សាសរុប ដែលនាំឱ្យមានគម្លាតដ៏ធំពាក់ព័ន្ធនឹងការទទួលបានអត្ថប្រយោជន៍គាំពារសង្គមពីកម្មវិធី។ បញ្ហាខ្សែច្រវាក់ការផ្គត់ផ្គង់ស្បៀងកាន់តែស្មុគស្មាញដល់ការពង្រីកការអនុវត្តកម្មវិធី ដោយសារហេដ្ឋារចនាសម្ព័ន្ធនិងទីផ្សារមិនទាន់ទូលាយ ជាមូលហេតុរាំងសមត្ថភាពសហគមន៍កសិកម្ម និងកសិករខ្នាតតូចចូលរួមផ្គត់ផ្គង់ស្បៀងស្រស់មានគុណភាពដល់សាលារៀន[24]។ តម្រូវការកសាងសមត្ថភាព នៅតែជាបញ្ហាប្រឈម ដោយសារសមត្ថភាពបុគ្គលិកតាមសាលាបឋមសិក្សាគោលដៅនិងអាជ្ញាធរមូលដ្ឋាននៅមានកម្រិត ជាពិសេសពាក់ព័ន្ធនឹងនីតិវិធីនៃការជ្រើសរើសអ្នកផ្គត់ផ្គង់ស្បៀង ការអនុវត្តកម្មវិធី សុវត្ថិភាពចំណីអាហារ ប្រព័ន្ធព័ត៌មានគ្រប់គ្រងកម្មវិធីអាហារតាមសាលារៀន និងការពិនិត្យតាមដាននិងវាយតម្លៃកម្មវិធីដែលមានប្រសិទ្ធភាព[25]។

## ១.៣. អាទិភាព

ភាពជោគជ័យនៃកម្មវិធីផ្តល់អាហារតាមសាលារៀនពឹងផ្អែកលើយុទ្ធសាស្ត្រចម្រុះ រួមមានក្របខ័ណ្ឌច្បាប់ ប្រតិបត្តិការ សន្តិសុខស្បៀង ការយល់ដឹងរបស់សហគមន៍ សុខភាព អាហារូបត្ថម្ភ ការអភិវឌ្ឍ កសិកម្ម សេដ្ឋកិច្ច អភិបាលកិច្ចរឹងមាំ និងភាពជាដៃគូ។ ផែនការសកម្មភាពអនុវត្តគោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀន ២០២៤-២០៣០ នឹងផ្តល់ជាផែនទីដ៏សំខាន់ ក្នុងការស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមខាងលើ ប៉ុន្តែដោយសារធនធានមានកម្រិត ទើបតម្រូវឱ្យមានការកំណត់វិធានការដោះស្រាយតាមអាទិភាពសំខាន់ៗ ដូចខាងក្រោម៖



[24] របាយការណ៍សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ របស់អង្គការស្បៀងនិងកសិកម្មនៃអង្គការសហប្រជាជាតិ ឆ្នាំ២០២៣

[25] របាយការណ៍វគ្គបណ្តុះបណ្តាលពីកម្មវិធីផ្តល់អាហារតាមសាលារៀនដល់ថ្នាក់ក្រោមជាតិរបស់ក្រសួងអប់រំ យុវជន និងកីឡាឆ្នាំ២០២៣

## អភិវឌ្ឍក្របខណ្ឌច្បាប់ និងយន្តការ

អាទិភាពសំខាន់គឺ ការបញ្ចប់និងអនុម័តសេចក្តីណែនាំប្រតិបត្តិស្តីពីការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន និងបញ្ចូលការពិនិត្យឡើងវិញនៃការកំណត់ តួនាទីរបស់អ្នកពាក់ព័ន្ធទាំងអស់ដែលមានក្នុងគោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀន នីតិវិធីអនុវត្តកម្មវិធី នីតិវិធីនៃសាកសួរថ្លៃ ការដឹកជញ្ជូនស្បៀង និងការត្រួតពិនិត្យ។ ការអនុម័តលើគោលការណ៍ណែនាំទាំងនេះ នឹងធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួល ធានានិរន្តរភាពនិងលើកកម្ពស់គណនេយ្យភាព ការធ្វើឱ្យមានភាពស្របគ្នារវាងកម្មវិធីទៅនឹងគោលដៅអប់រំ និងសុខភាព។

## លើកកម្ពស់សន្តិសុខស្បៀងដល់សិស្ស និងគ្រួសារសិស្ស

ផ្តល់អាហារជូនសិស្សផ្តោតសំខាន់ទៅលើការកែលម្អសុខភាព និងអាហារូបត្ថម្ភ តាមរយៈការផ្តល់អាហារដែលមានអាហារូបត្ថម្ភចម្រុះ មានប្រភព ច្បាស់លាស់ និង/ឬអាហារដែលមានបញ្ចូលមីក្រូសារជាតិ ដែលទាក់ទាញសិស្សឱ្យមករៀនទៀងទាត់ ទទួលបានលទ្ធផលសិក្សាល្អ និងការលូតលាស់រាងកាយ បញ្ញា ស្មារតីល្អប្រសើរ កាត់បន្ថយការចំណាយគ្រួសារ ជួយបង្កើនសន្តិសុខស្បៀងក្នុងសហគមន៍។

## លើកកម្ពស់ការយល់ដឹងរបស់សហគមន៍

បង្កើនការយល់ដឹងក្នុងសហគមន៍អំពីសារៈសំខាន់ នៃកម្មវិធីផ្តល់អាហារតាមសាលារៀន អាហារូបត្ថម្ភ ពង្រឹងតួនាទី និងការចូលរួមរបស់អាជ្ញាធរមូលដ្ឋានក្នុងការអនុវត្តកម្មវិធី និងការបង្កើនភាពអង់អាចដល់សហគមន៍ ដើម្បីបង្កើតយុទ្ធសាស្ត្រអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនប្រកបដោយបរិយាបន្ន និងមានប្រសិទ្ធភាព

បង្កើតមេរៀនពិសោធន៍ឈានទៅការពង្រីកការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន។

## លើកកម្ពស់សុខភាពនិងអាហារូបត្ថម្ភ

ផ្តល់អាហារដែលមានសុវត្ថិភាព ចម្រុះ និងមានអាហារូបត្ថម្ភគ្រប់គ្រាន់ ដោយអភិវឌ្ឍស្តង់ដាអាហារូបត្ថម្ភសមស្របទៅនឹងបរិបទប្រទេស ការអនុវត្តស្តង់ដាសុវត្ថិភាពម្ហូបអាហារ ការធ្វើពិពិធកម្មមុខម្ហូបនិងការតភ្ជាប់ជាមួយការអប់រំ សុខភាព និងអាហារូបត្ថម្ភ ជាពិសេស ការសាងសង់ ថែទាំនិងជួសជុលហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈចាំបាច់ ដើម្បីធានាថាកម្មវិធីត្រូវបានអនុវត្តប្រកបដោយសុវត្ថិភាព និងមានប្រសិទ្ធភាព។

## ជំរុញការអភិវឌ្ឍកសិកម្មនិងសេដ្ឋកិច្ចក្នុងសហគមន៍

គាំទ្រខ្សែច្រវាក់កសិកម្មក្នុងស្រុកដោយប្រើប្រាស់កសិផលពីការដាំដុះនៅក្នុងតំបន់ មានប្រភពច្បាស់លាស់និងមានសុវត្ថិភាព រួមចំណែកដល់ការជំរុញឱ្យមានកំណើនសេដ្ឋកិច្ចមូលដ្ឋានបានកាន់តែប្រសើរ។

## ពង្រឹងអភិបាលកិច្ច ភាពជាដៃគូ និង ការសម្របសម្រួលអន្តរវិស័យ

បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងកម្មវិធី ការពង្រឹងកិច្ចសហការអន្តរវិស័យ ដើម្បីជំរុញការអនុវត្តកម្មវិធីប្រកបដោយប្រសិទ្ធភាព។ ការបង្កើតភាពជាដៃគូជាមួយអង្គការជាតិ អន្តរជាតិ វិស័យឯកជន ក្នុងការទទួលបានការគាំទ្របច្ចេកទេស និងការកៀរគរធនធានបន្ថែមសម្រាប់អនុវត្តកម្មវិធី។

# ២.យុទ្ធសាស្ត្រ



ផែនការសកម្មភាពអនុវត្តគោលនយោបាយស្តីពី ការផ្តល់អាហារតាមសាលារៀនត្រូវបានរៀបចំឡើង ដោយអនុលោមតាមយុទ្ធសាស្ត្រទាំង៦នៃគោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀន ដូចខាងក្រោម៖

❶ អភិវឌ្ឍក្របខ័ណ្ឌច្បាប់ និងយន្តការ

❷ លើកកម្ពស់សន្តិសុខស្បៀងដល់សិស្ស និងគ្រួសារសិស្ស

❸ លើកកម្ពស់ការយល់ដឹងរបស់សហគមន៍

❹ លើកកម្ពស់សុខភាព និងអាហារូបត្ថម្ភ

❺ ជំរុញការអភិវឌ្ឍកសិកម្ម និងសេដ្ឋកិច្ចក្នុងសហគមន៍

❻ ពង្រឹងអភិបាលកិច្ច ភាពជាដៃគូ និងការសម្របសម្រួលអន្តរវិស័យ

នៅក្នុងយុទ្ធសាស្ត្រទាំង ៦ខាងលើ មានយុទ្ធសាស្ត្ររង ២៤ ដែលជាការចង្អុលបង្ហាញទិសដៅដើម្បីកំណត់សកម្មភាពជាក់លាក់តាមយុទ្ធសាស្ត្រនីមួយៗដូចខាងក្រោម៖

## យុទ្ធសាស្ត្រទី១៖ អភិវឌ្ឍក្របខ័ណ្ឌច្បាប់ និងយន្តការ

| | |
|---|---|
| | រៀបចំលិខិតបទដ្ឋានគតិយុត្ត និងយន្តការនានា ដើម្បីជានាការអនុវត្តគោលនយោបាយឱ្យមាន ប្រសិទ្ធភាព បរិយាបន្ន និងសមធម៌ ដោយកំណត់ឱ្យមានកិច្ចសហការនិងភារកិច្ចរបស់ភាគីពាក់ព័ន្ធ |
| | លើកកម្ពស់ ផ្សព្វផ្សាយ និងជំរុញការអនុវត្តគោលនយោបាយជាតិ ក្របខ័ណ្ឌច្បាប់ យន្តការពាក់ព័ន្ធដែលមានស្រាប់ និងយន្តការដែលនឹងត្រូវបង្កើតថ្មី |
| | បង្កើតផែនការសកម្មភាពអនុវត្តគោលនយោបាយផ្តល់អាហារតាមសាលារៀន ដោយកំណត់សកម្មភាពជាក់លាក់ ពេលវេលា ធនធាន និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ |

## យុទ្ធសាស្ត្រទី២៖ លើកកម្ពស់សន្តិសុខស្បៀងដល់សិស្ស និងគ្រួសារសិស្ស

- ពង្រឹងយន្តការកំណត់សាលារៀនគោលដៅសម្រាប់កម្មវិធី
- ធានាការផ្តល់អាហារទាន់ពេលវេលាដល់សិស្សជារៀងរាល់ថ្ងៃសិក្សា
- ធានាកាត់បន្ថយចំណាយរបស់គ្រួសារកុមារមានស្ថានភាពលំបាក

## យុទ្ធសាស្ត្រទី៣៖ លើកកម្ពស់ការយល់ដឹងរបស់សហគមន៍

- លើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់កម្មវិធីផ្តល់អាហារតាមសាលារៀន
- បង្ហាញពីផលជះដែលទទួលបានពីកម្មវិធីផ្តល់អាហារតាមសាលារៀន
- ជំរុញចលនាសហគមន៍ អាជ្ញាធរដែនដីឱ្យចូលរួមគាំទ្រនិងឧបត្ថម្ភកម្មវិធីផ្តល់អាហារតាមសាលារៀន
- ពង្រីកកម្មវិធីផ្តល់អាហារតាមសាលារៀនតាមលទ្ធភាព និងស្ថានភាពជាក់ស្តែង
- លើកកម្ពស់ការទទួលបានអាហារប្រកបដោយសមធម៌និងបរិយាបន្ន

## យុទ្ធសាស្ត្រទី៤៖ លើកកម្ពស់សុខភាពនិងអាហារូបត្ថម្ភ

- អភិវឌ្ឍ និងអនុវត្តស្តង់ដាអាហារូបត្ថម្ភដោយផ្អែកលើបរិបទជាក់លាក់
- ជំរុញអនុវត្តស្តង់ដាសុវត្ថិភាពម្ហូបអាហារ
- ជំរុញការធ្វើពិពិធកម្មមុខម្ហូបសម្រាប់កម្មវិធី ធានាការផ្សារភ្ជាប់កម្មវិធីផ្តល់អាហារតាមសាលារៀន ជាមួយនឹងកម្មវិធីសិក្សា អប់រំសុខភាព និងអាហារូបត្ថម្ភ
- អភិវឌ្ឍនិងធានាការថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងសម្ភារៈចាំបាច់សម្រាប់ដំណើរការកម្មវិធី

## យុទ្ធសាស្ត្រទី៥៖ ជំរុញការអភិវឌ្ឍ កសិកម្មនិងសេដ្ឋកិច្ចក្នុងសហគមន៍

| | |
|---|---|
| | លើកកម្ពស់ការយល់ដឹងអ្នកផ្គត់ផ្គង់ ឬកសិករក្នុងសហគមន៍អំពីតម្រូវការនៃការផ្គត់ផ្គង់ស្បៀងដល់ កម្មវិធីផ្តល់អាហារតាមសាលារៀន |
| | ចងក្រងសហគមន៍ដើម្បីផ្គត់ផ្គង់កសិផលដល់កម្មវិធីផ្តល់អាហារតាមសាលារៀន |
| | អភិវឌ្ឍនិងពង្រឹងការអនុវត្តនីតិវិធីការជ្រើសរើសអ្នកផ្គត់ផ្គង់ក្នុងសហគមន៍ |
| | បណ្តុះស្មារតីសិស្សនិងសហគមន៍ឱ្យស្រឡាញ់និងផ្តល់តម្លៃឱ្យអាហារដែលប្រើប្រាស់កសិផលក្នុងសហគមន៍ |

## យុទ្ធសាស្ត្រទី៦៖ ពង្រឹងអភិបាលកិច្ច ភាពជាដៃគូ និងការសម្របសម្រួលអន្តរវិស័យ

| | |
|---|---|
| | ផ្សារភ្ជាប់គោលនយោបាយវិស័យពាក់ព័ន្ធនានាជាមួយនឹងកម្មវិធីផ្តល់អាហារតាមសាលារៀន |
| | វិភាជថវិកាគាំទ្រកម្មវិធីផ្តល់អាហារតាមសាលារៀនឱ្យបានសមស្រប |
| | អភិវឌ្ឍធនធានមនុស្សលើផ្នែកបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងនិងអនុវត្តកម្មវិធីផ្តល់ អាហារតាមសាលារៀន |
| | ពង្រឹងយន្តការសម្របសម្រួលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងនិងអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន |
| | លើកកម្ពស់ការចូលរួមទៀងទាត់និងសកម្មពីដៃគូអភិវឌ្ឍន៍ វិស័យឯកជន សប្បុរជន និងសហគមន៍ ក្នុងការគាំទ្របច្ចេកទេសសម្ភារៈឬហិរញ្ញវត្ថុដល់កម្មវិធីផ្តល់អាហារតាមសាលារៀន។ |

## ៣. តារាងម៉ាទ្រិកផែនការសកម្មភាពអនុវត្តគោលនយោបាយ

ផែនការសកម្មភាពអនុវត្តគោលនយោបាយស្តីពីផ្តល់អាហារតាមសាលារៀនមានពីរដំណាក់កាលគឺ ដំណាក់កាលទី១ ចាប់ពីឆ្នាំ ២០២៤-២០៣០ និងដំណាក់កាលទី២ ចាប់ពីឆ្នាំ២០៣១-២០៣៥។

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| **យុទ្ធសាស្ត្រទី១៖ អភិវឌ្ឍក្របខ័ណ្ឌច្បាប់ និងយន្តការ** | | | | | | | | | | | |
| យុទ្ធសាស្ត្ររងទី១.១៖ រៀបចំលិខិតបទដ្ឋានគតិយុត្តិ និងយន្តការនានា ដើម្បីជានាការអនុវត្តគោលនយោបាយឱ្យមានប្រសិទ្ធភាព បរិយាបន្ន និងសមធម៌ដោយកំណត់ឱ្យមានកិច្ចសហការ និងភារកិច្ចរបស់ភាគីពាក់ព័ន្ធ | | | | | | | | | | | |
| ១.១.១ | រៀបចំប្រកាសស្តីពីការបង្កើតគណៈកម្មការដឹកនាំ និងគ្រប់គ្រងការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ | ប្រកាសស្តីពីការបង្កើតគណៈកម្មការដឹកនាំ និងគ្រប់គ្រងការអនុវត្តកម្មវិធីបានរៀបចំផ្សព្វផ្សាយ | x | | | | | | | អ.យ.ក. | – |
| ១.១.២ | រៀបចំសេចក្តីសម្រេចស្តីពីការតែងតាំងគណៈកម្មការដឹកនាំ និងគ្រប់គ្រងការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន | សេចក្តីសម្រេចស្តីពីការតែងតាំងគណៈកម្មការដឹកនាំ និងគ្រប់គ្រងការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់ | x | | | | | | | អ.យ.ក. | – |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| | ដោយប្រើប្រាស់កសិផលក្នុងសហគមន៍ | កសិផលក្នុងសហគមន៍បានរៀបចំផ្សព្វផ្សាយនិងអនុវត្ត | | | | | | | | | |
| ១.១.៣ | រៀបចំប្រកាសអន្តរក្រសួងស្តីពីប្រាក់ឧបត្ថម្ភអាហារសិស្ស ប្រាក់ឧបត្ថម្ភចុងភៅ វិធីសាស្ត្រកំណត់ចំនួនសិស្សត្រូវទទួលអាហារនិងចំនួនចុងភៅ និងផ្ទះបាយសាលារៀន ក្រោមកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ | ប្រកាសអន្តរក្រសួងស្តីពីប្រាក់ឧបត្ថម្ភអាហារសិស្ស ប្រាក់ឧបត្ថម្ភចុងភៅ វិធីសាស្ត្រកំណត់ចំនួនសិស្សត្រូវទទួលអាហារនិងចំនួនចុងភៅ និងផ្ទះបាយសាលារៀនបានអនុម័ត | x | | | | | | | ស.ហ.វ.<br>ក.ជ.គ.ស.<br>អ.យ.ក. | – |
| ១.១.៤ | រៀបចំប្រកាសដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំប្រតិបត្តិកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ | សៀវភៅណែនាំប្រតិបត្តិកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍បានប្រកាសដាក់ឱ្យប្រើប្រាស់ | | x | | | | | | អ.យ.ក. | – |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| ១.១.៥ | រៀបចំក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃកម្មវិធីផ្តល់អាហារតាមសាលារៀន | ក្របខ័ណ្ឌពិនិត្យតាមដានត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | | x | | | | | | អ.យ.ក. ក.ជ.គ.ស. ដៃគូអភិវឌ្ឍន៍ រដ្ឋបាលថ្នាក់ក្រោមជាតិ | ៤០ |
| ១.១.៦ | ពិនិត្យឡើងវិញក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃកម្មវិធីផ្តល់អាហារតាមសាលារៀន | ក្របខ័ណ្ឌពិនិត្យតាមដានត្រូវបានពិនិត្យ និងធ្វើបច្ចុប្បន្នភាព | | | | | | x | | អ.យ.ក. ក.ជ.គ.ស. ដៃគូអភិវឌ្ឍន៍ រដ្ឋបាលថ្នាក់ក្រោមជាតិ | ៤០ |
| ១.១.៧. | ធ្វើបច្ចុប្បន្នកម្មសៀវភៅណែនាំប្រតិបត្តិកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ដោយផ្អែកលើមេរៀនបទពិសោធន៍បរិស្ថាន សង្គម និងសេដ្ឋកិច្ច | សៀវភៅណែនាំប្រតិបត្តិកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍បានធ្វើបច្ចុប្បន្នភាព | | | | | | x | | អ.យ.ក. | ១២០ |

| | សកម្មភាព | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| យុទ្ធសាស្ត្រវងទី១.២៖ លើកកម្ពស់ ផ្សព្វផ្សាយ និងជំរុញការអនុវត្តគោលនយោបាយជាតិ ក្របខ័ណ្ឌច្បាប់ យន្តការពាក់ព័ន្ធដែលមានស្រាប់ និងយន្តការដែលនឹងត្រូវបង្កើតថ្មី | | | | | | | | | | | |
| ១.២.១ | សហការ ជាមួយស្ថាប័នពាក់ព័ន្ធ ផ្សព្វផ្សាយលទ្ធផលនៃការអនុវត្តគោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀន | របាយការណ៍នៃការផ្សព្វផ្សាយគោលនយោបាយ ផែនការសកម្មភាព និងក្របខ័ណ្ឌគតិយុត្ត | | | x | | x | | | អ.យ.ក. ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ | ២០០/ឆ្នាំ |
| ១.២.២ | ជំរុញការអនុវត្តគោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀន និងផែនការសកម្មភាព | លិខិតបទដ្ឋាន សេចក្តីណែនាំ និងកិច្ចប្រជុំជំរុញការអនុវត្តគោលនយោបាយ និងផែនការសកម្មភាព | x | x | x | x | x | x | x | អ.យ.ក. ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ | – |
| ១.២.៣ | បន្សីផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធឱ្យឆ្លើយតបផែនការសកម្មភាពអនុវត្តគោលនយោបាយផ្តល់អាហារតាមសាលារៀន | ក្រសួងស្ថាប័នបានអនុម័តផែនការប្រតិបត្តិប្រចាំឆ្នាំឆ្លើយតបទៅនឹងផែនការសកម្មភាពអនុវត្តគោលនយោបាយផ្តល់អាហារតាមសាលារៀន | | | x | x | x | x | x | អ.យ.ក. ក្រសួង ស្ថាប័នពាក់ព័ន្ធ | – |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| ១.២.៤ | ដាក់បញ្ចូលកម្មវិធីផ្តល់អាហារតាមសាលារៀនក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ និងផែនការប្រតិបត្តិប្រចាំឆ្នាំ | ភាគរយសាលារៀនបានដាក់បញ្ចូល កម្មវិធីផ្តល់អាហារតាមសាលារៀនក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍សាលារៀន និងផែនការប្រតិបត្តិប្រចាំឆ្នាំ | | | x | x | x | x | x | ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ | – |
| ១.២.៥ | ជំរុញរៀបចំផែនការអភិវឌ្ឍកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ឱ្យឆ្លើយតបគោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀន | ភាគរយរដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ បានដាក់បញ្ចូលកម្មវិធីផ្តល់អាហារតាមសាលារៀនទៅក្នុងផែនការវិនិយោគបីឆ្នាំរំកិល | | | x | x | x | x | x | ម.ផ. រដ្ឋបាលថ្នាក់ក្រោមជាតិ | – |
| ១.២.៦ | ជំរុញការដាក់បញ្ចូលកម្មវិធីផ្តល់អាហារតាមសាលារៀនក្នុងការពិនិត្យឡើងវិញគោលនយោបាយយុទ្ធសាស្រ្តជាតិនានា ដើម្បី | ប្រយោជន៍នៃការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនត្រូវបានរំលេចក្នុងកម្មវិធីអាទិភាព និងយុទ្ធសាស្រ្តនានារបស់ជាតិ | x | | | | | x | x | ក្រសួង ស្ថាប័នពាក់ព័ន្ធ | – |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| | បង្កើនតួនាទីនៃការរួមចំណែកការផ្ដល់អាហារតាមសាលារៀន | | | | | | | | | | |
| យុទ្ធសាស្ត្រវងទី១.៣៖ បង្កើតផែនការសកម្មភាពគោលនយោបាយស្ដីពីការផ្ដល់អាហារតាមសាលារៀនដោយកំណត់សកម្មភាពជាក់លាក់ ពេលវេលា ធនធាន និងការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ | | | | | | | | | | | |
| ១.៣.១ | រៀបចំផែនការសកម្មភាពអនុវត្តគោលនយោបាយផ្ដល់អាហារតាមសាលារៀនដោយកំណត់សកម្មភាពជាក់លាក់ ធនធាន ពេលវេលា និងការទទួលខុសត្រូវរបស់ក្រសួងពាក់ព័ន្ធ | ផែនការសកម្មភាពអនុវត្តគោលនយោបាយផ្ដល់អាហារតាមសាលារៀនបានអនុម័ត និងផ្សព្វផ្សាយ | | X | | | | X | X | អ.យ.ក. ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ | ១២០/ឆ្នាំ |
| ១.៣.២ | វាយតម្លៃការអនុវត្តផែនការសកម្មភាពអនុវត្តគោលនយោបាយផ្ដល់អាហារតាមសាលារៀនប្រចាំឆ្នាំ | ការវាយតម្លៃការអនុវត្តផែនការសកម្មភាពអនុវត្តគោលនយោបាយផ្ដល់អាហារតាមសាលារៀនប្រចាំឆ្នាំ | | X | X | X | X | X | X | អ.យ.ក. ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ | ១០០/ឆ្នាំ |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| ១.៣.៣ | ពិនិត្យឡើងវិញពាក់កណ្ដាលអាណត្តិនៃផែនការសកម្មភាពអនុវត្តគោលនយោបាយផ្ដល់អាហារតាមសាលារៀន | ផែនការសកម្មភាពអនុវត្តគោលនយោបាយផ្ដល់អាហារតាមសាលារៀនបានរៀបចំពិនិត្យ និងកែលម្អឡើងវិញនៅពាក់កណ្ដាល អាណត្តិ | | | | | | x | | អ.ឃ.ក. | ៤០០ |
| **យុទ្ធសាស្ត្រទី២៖ លើកកម្ពស់សន្តិសុខស្បៀងដល់សិស្ស និងគ្រួសារសិស្ស** | | | | | | | | | | | |
| យុទ្ធសាស្ត្រវង២.១៖ ពង្រឹងយន្តការកំណត់សាលារៀនគោលដៅសម្រាប់អនុវត្តកម្មវិធី | | | | | | | | | | | |
| ២.១.១ | រៀបចំ ក្របខ័ណ្ឌទិន្នន័យ និងលក្ខណៈវិនិច្ឆ័យស្តង់ដាកំណត់ជ្រើសរើសសាលារៀនគោលដៅ | ក្របខ័ណ្ឌទិន្នន័យ និងលក្ខណៈវិនិច្ឆ័យជ្រើសរើសសាលារៀនគោលដៅត្រូវបានកំណត់ | | | x | | | | | ក.ជ.គ.ស. អ.ឃ.ក. និងដៃគូអភិវឌ្ឍន៍ | ៦០ |
| ២.១.២ | រៀបចំនីតិវិធីប្រតិបត្តិការស្តង់ដា (SOPs) សម្រាប់ការកំណត់ជ្រើសរើសសាលារៀនគោលដៅ | នីតិវិធីប្រតិបត្តិការស្តង់ដា (SOPs) សម្រាប់ការកំណត់ជ្រើសរើសសាលារៀនគោលដៅត្រូវបានរៀបចំ | | | x | | | | | ក.ជ.គ.ស. អ.ឃ.ក. និងដៃគូអភិវឌ្ឍន៍ | ៨០ |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| ២.១.៣ | រៀបចំសេចក្តីណែនាំស្តីពីការកំណត់គោលដៅថ្មី និងសកម្មភាព សម្រាប់គាំទ្រការផ្តល់អាហារតាមសាលារៀន | យន្តការកំណត់គោលដៅថ្មីបានរៀបចំ អនុម័ត និងដាក់ឱ្យប្រើប្រាស់ | | | | x | | | | អ.យ.ក.<br>ក.ជ.គ.ស.<br>ក្រសួង ស្ថាប័នពាក់ព័ន្ធ | – |
| យុទ្ធសាស្ត្រទី២.២៖ ធានាការផ្តល់អាហារទាន់ពេលវេលាដល់សិស្សជារៀងរាល់ថ្ងៃសិក្សា | | | | | | | | | | | |
| ២.២.១ | ពង្រឹងតួនាទីដឹកនាំ គ្រប់គ្រងរបស់គណៈកម្មការ ថ្នាក់ក្រោមជាតិក្នុងការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន | គណៈកម្មការដឹកនាំ និងគ្រប់គ្រងចំពោះកិច្ចការអនុវត្តកម្មវិធី ថ្នាក់ក្រោមជាតិ មានដំណើរការ | | x | x | x | x | x | x | អ.យ.ក.<br>រដ្ឋបាលថ្នាក់ក្រោមជាតិ | – |
| ២.២.២ | រៀបចំប្រកាសស្តីពីនីតិវិធីនៃការអនុវត្តថវិកាសម្រាប់ កម្មវិធីផ្តល់អាហារតាមសាលារៀន | ប្រកាសស្តីពីនីតិវិធីនៃការអនុវត្តថវិកាសម្រាប់ កម្មវិធីផ្តល់អាហារតាមសាលារៀនត្រូវបានរៀបចំ | | | x | | | | | ក.ជ.គ.ស. | ៥ |
| ២.២.៣ | ផលិតសម្ភារៈនិងកញ្ចប់វគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តកម្មវិធីសម្រាប់ស្វ័យសិក្សា | សម្ភារៈ និងកញ្ចប់វគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តកម្មវិធីបានផលិតសម្រាប់ស្វ័យសិក្សា ការរៀន | | | x | | | x | x | អ.យ.ក.<br>ដៃគូអភិវឌ្ឍន៍ | ២០០/ឆ្នាំ |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| | ការរៀនអនឡាញ និងការសិក្សាពីគ្នាទៅវិញទៅមក | អនឡាញ និងការសិក្សាពីគ្នាទៅវិញទៅមកបានផលិត និងផ្សព្វផ្សាយ | | | | | | | | | |
| ២.២.៤ | អភិវឌ្ឍសមត្ថភាពគណៈកម្មការដឹកនាំនិងគ្រប់គ្រងចំពោះកិច្ចការអនុវត្តកម្មវិធី និងអ្នកពាក់ព័ន្ធផ្សេងទៀតស្ដីពីការអនុវត្តកម្មវិធីតាមមធ្យោបាយផ្សេងៗគ្នាស្របតាមធនធាន និងតម្រូវការ | ចំនួនគ្រូបង្រៀន ចុងភៅនិងអ្នកពាក់ព័ន្ធផ្សេងទៀតបានចូលរួមសកម្មភាពអភិវឌ្ឍសមត្ថភាព | x | x | x | x | x | x | x | អ.យ.ក. ដៃគូអភិវឌ្ឍន៍ រដ្ឋបាលថ្នាក់ក្រោមជាតិ | ៨០/ឆ្នាំ |
| ២.២.៥ | ជ្រើសរើសអ្នកផ្គត់ផ្គង់ និងចុងភៅប្រកបដោយតម្លាភាព និងទាន់ពេលវេលាមុនចាប់ផ្ដើមដំណើរការឆ្នាំសិក្សាថ្មី | ភាគរយសាលារៀនគោលដៅមានអ្នកផ្គត់ផ្គង់ និងចុងភៅ មុនចាប់ផ្ដើមដំណើរការឆ្នាំសិក្សាថ្មី | x | x | x | x | x | x | x | អ.យ.ក. ក.ស.ក. រដ្ឋបាលថ្នាក់ក្រោមជាតិ | – |

| សកម្មភាព | | សូចនាករ | ក្របខណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| ២.២.៦ | ពិនិត្យលទ្ធភាពផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាល ជូនដល់ចុងភៅ | របាយការណ៍លទ្ធផលនៃការសិក្សាលទ្ធភាពផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាលដល់ចុងភៅសាលារៀន | | x | | | | | | ក.ជ.គ.ស.<br>អ.យ.ក.<br>ស.អ.យ. | – |
| ២.២.៧ | ផ្តល់អាហារប្រកបដោយអាហារូបត្ថម្ភចម្រុះ និងមានសុវត្ថិភាពជូនដល់សិស្សតាមសាលារៀនគោលដៅឱ្យបានទៀងទាត់រៀងរាល់ថ្ងៃសិក្សា | អាហារូបត្ថម្ភចម្រុះនិងមានសុវត្ថិភាពបានផ្តល់ជូនដល់សិស្សជារៀងរាល់ថ្ងៃសិក្សា | x | x | x | x | x | x | x | អ.យ.ក. | ៤០០០០/ឆ្នាំ |
| ២.២.៨ | ចែករំលែកបទពិសោធន៍នៃការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន | ចំនួនវេទិកា/កិច្ចប្រជុំដែលបានរៀបចំ | x | x | x | x | x | x | x | អ.យ.ក.<br>ដៃគូអភិវឌ្ឍន៍<br>រដ្ឋបាលថ្នាក់ក្រោមជាតិ | ៦០/ឆ្នាំ |
| ២.២.៩ | សិក្សា និងអនុវត្ត គំរូផ្សេងៗស្តីពីការផ្តល់អាហារ ដែលបត់បែន | គំរូជាច្រើននៃការផ្តល់អាហារបានសិក្សា និងដាក់ឱ្យអនុវត្ត | | | x | x | x | x | x | អ.យ.ក.<br>ក.ជ.គ.ស. | – |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័ន ទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| | តាមលក្ខខណ្ឌភូមិសាស្ត្រ ស្ថានភាពសេដ្ឋកិច្ច ទំហំផលិតផលក្នុងស្រុក និងកម្រិតនៃការចូលរួមរបស់សហគមន៍ | | | | | | | | | ដៃគូអភិវឌ្ឍន៍ រដ្ឋបាលថ្នាក់ក្រោមជាតិ | |
| ២.២.១០ | ពិនិត្យភាពទៀងទាត់នៃការចម្អិនអាហារជូនដល់សិស្សតាមសាលារៀនតាមរយៈការប្រើប្រាស់បច្ចេកវិទ្យា | សិស្សទទួលបានអាហារតាមសាលារៀនជាប្រចាំនិងទៀងទាត់ | x | x | x | x | x | x | x | អ.យ.ក. ក្រសួង ស្ថាប័នពាក់ព័ន្ធ | – |
| យុទ្ធសាស្ត្រទី២.៣៖ ធានាកាត់បន្ថយចំណាយរបស់គ្រួសារកុមារមានស្ថានភាពលំបាក | | | | | | | | | | | |
| ២.៣.១ | សហការជាមួយសាលារៀនដែលមានទីតាំងនៅក្នុង ឬក្បែរវត្តអារាម ឬវិហារសាសនា ឬសហគមន៍ដើម្បីចូលរួមផ្តល់អាហារជូនដល់សិស្ស តាមលទ្ធភាពនិងរូបភាពផ្សេងៗ | ភាគរយសាលារៀនទទួលបានការគាំទ្រពីវត្តអារាម ឬវិហារសាសនា ឬសហគមន៍ដើម្បីផ្តល់អាហារតាមសាលារៀន | x | x | x | x | x | x | x | ក.ក.ធ.ស. វត្តអារាម ដៃគូអភិវឌ្ឍន៍ វិស័យឯកជន | – |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| ២.៣.២ | ជំរុញ និងគាំទ្រគ្រួសារសិស្ស ចូលរួមក្នុងការដាំដុះ ចិញ្ចឹមសត្វ និងលក់ផលិតផលទៅកាន់សហគមន៍ និងទីផ្សារ | ចំនួនគ្រួសារសិស្ស ចូលរួមក្នុងការដាំដុះ ចិញ្ចឹមសត្វ និងលក់ផលិតផលទៅកាន់សហគមន៍ និងទីផ្សារ | x | x | x | x | x | x | x | ក.ស.ក ដៃគូអភិវឌ្ឍន៍ រដ្ឋបាលថ្នាក់ក្រោមជាតិ | ៤០/ឆ្នាំ |
| **យុទ្ធសាស្ត្រទី៣៖ លើកកម្ពស់ការយល់ដឹងរបស់សហគមន៍** | | | | | | | | | | | |
| យុទ្ធសាស្ត្ររង៣.១៖ លើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់កម្មវិធីផ្តល់អាហារតាមសាលារៀន | | | | | | | | | | | |
| ៣.១.១ | បង្កើនការយល់ដឹងអំពីសារៈសំខាន់នៃកម្មវិធីផ្តល់អាហារតាមសាលារៀនជូនដល់សាធារណជន | របាយការណ៍នៃសកម្មភាពផ្សព្វផ្សាយស្តីពីកម្មវិធីផ្តល់អាហារតាមសាលារៀន | x | x | x | x | x | x | x | អ.យ.ក. | ៤០/ឆ្នាំ |
| ៣.១.២ | ផលិតសម្ភារៈអប់រំ និផ្សព្វផ្សាយអំពីសារៈសំខាន់ស្តីពីការផ្តល់អាហារតាមសាលារៀនទៅកាន់សហគមន៍ និងអ្នកពាក់ព័ន្ធ | ប្រភេទសម្ភារៈអប់រំបានបង្កើត និងផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ | x | x | x | x | x | x | x | អ.យ.ក. | ៤០/ឆ្នាំ |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| ៣.១.៣ | ស្ទង់មតិលើភាពពេញចិត្ត របស់សហគមន៍ ស្តីពីការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន | កម្រិតនៃភាពពេញចិត្តរបស់សហគមន៍លើការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនត្រូវបានកំណត់ | | | x | | | x | x | អ.យ.ក<br>ក.ជ.គ.ស.<br>ដៃគូអភិវឌ្ឍន៍ | ៨០/ឆ្នាំ |
| ៣.១.៤ | ចងក្រងនិងផ្សព្វផ្សាយឧត្តមានុវត្តន៍នៃការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន | ឧត្តមានុវត្តន៍នៃការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនត្រូវបានចងក្រងដោយអ្នកពាក់ព័ន្ធនិងផ្សព្វផ្សាយ | | x | x | x | x | x | x | ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>ដៃគូអភិវឌ្ឍន៍ | ៣០/ឆ្នាំ |
| យុទ្ធសាស្ត្រទី៣.២៖ បង្ហាញពីផលជះដែលទទួលបានពីកម្មវិធីផ្តល់អាហារតាមសាលារៀន | | | | | | | | | | | |
| ៣.២.១ | វាយតម្លៃកម្មវិធីបាក/ផលជះនៃការចូលរួមរបស់អ្នកផលិត អ្នកផ្គត់ផ្គង់ អាជីវករ សិស្សានុសិស្ស និងសហគមន៍ ក្នុងកម្មវិធីផ្តល់អាហារតាមសាលារៀន | របាយការណ៍វាយតម្លៃកម្មវិបាក/ផលជះនៃការចូលរួមរបស់អ្នកផលិត អ្នកផ្គត់ផ្គង់ អាជីវករ សិស្សានុសិស្ស និងសហគមន៍ក្នុងកម្មវិធីផ្តល់អាហារតាមសាលារៀនបានរៀបចំ | | | | x | | | | ក.ជ.គ.ស.<br>អ.យ.ក.<br>ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>ដៃគូអភិវឌ្ឍន៍ | ១៥០ |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| ៣.២.២ | ដាក់បញ្ចូលកម្មវិធីផ្តល់អាហារតាមសាលារៀនកម្ពុជាទៅក្នុងផែនការសកម្មភាពរបស់លេខាធិការដ្ឋានអាស៊ាន | របាយការណ៍វិភាគស្ថានភាពនៃការអនុវត្ត កម្មវិធីផ្តល់អាហារតាមសាលារៀនក្នុងតំបន់អាស៊ានត្រូវបានរៀបចំ និងផ្សព្វផ្សាយ | | x | | | | | | អ.យ.ក.<br>ក.ជ.គ.ស.<br>ដៃគូអភិវឌ្ឍន៍ | ៤០០ |
| ៣.២.៣ | សិក្សាស្រាវជ្រាវអំពីផលត្រឡប់នៃការវិនិយោគលើកម្មវិធីផ្តល់អាហារតាមសាលារៀនដើម្បីផ្តល់ភស្តុតាងសម្រាប់ការវិភាជថវិកា | របាយការណ៍ស្រាវជ្រាវត្រូវបានចងក្រង និងផ្សព្វផ្សាយ | | x | | | | | | ក.ជ.គ.ស.<br>អ.យ.ក.<br>ដៃគូអភិឌ្ឍន៍ | ៨០ |
| ៣.២.៤ | វាយតម្លៃកម្មវិបាក/ផលជះនៃអាហារូបត្ថម្ភ (nutrition impact) និងតម្លៃគំរូការផ្តល់អាហារតាមបែបផ្សេងៗ កែលម្អគុណភាពអាហារ | របាយការណ៍សិក្សា បានរៀបចំស្តីពីផលជះអាហារូបត្ថម្ភនិងតម្លៃគំរូការផ្តល់អាហារតាមបែបផ្សេងៗ | | | | | | | x | ក.ជ.គ.ស.<br>អ.យ.ក.<br>ដៃគូអភិវឌ្ឍន៍ | ២០០ |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| ៣.២.៥ | ផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវលើប្រធានបទពាក់ព័ន្ធនឹងអាហារតាម សាលារៀន | របាយការសិក្សាស្រាវជ្រាវដែលបានផ្សព្វផ្សាយ | | x | | | | x | x | អ.យ.ក.<br>ក.ជ.គ.ស.<br>ដៃគូអភិវឌ្ឍន៍ | ៤០/ឆ្នាំ |
| ៣.២.៦ | វាយតម្លៃកម្មវិបាក/ផលជះ នៃកម្មវិធីផ្តល់អាហារតាមសាលារៀន ដើម្បីផ្តល់ភស្តុតាងបែបវិទ្យាសាស្ត្រ បង្ហាញពីសារៈសំខាន់ និងកម្មវិបាក/ផលជះនៃកម្មវិធី | ចំនួនរបាយការណ៍វាយតម្លៃ | | | | x | | | | ក.ជ.គ.ស.<br>អ.យ.ក.<br>ដៃគូអភិវឌ្ឍន៍ | ២០០ |
| យុទ្ធសាស្ត្រទី៣.៣៖ ជំរុញចលនាសហគមន៍ អាជ្ញាធរដែនដី ឱ្យចូលរួមគាំទ្រ និងឧបត្ថម្ភកម្មវិធីផ្តល់អាហារតាមសាលារៀន | | | | | | | | | | | |
| ៣.៣.១ | រៀបចំវេទិកាសាធារណៈនៅថ្នាក់ក្រោមជាតិលើការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន | របាយការណ៍រៀបចំវេទិកាសាធារណៈថ្នាក់ក្រោមជាតិ ស្តីពីការផ្តល់អាហារតាមសាលារៀន | x | x | x | x | x | x | x | ម.ផ.<br>អ.យ.ក.<br>ដៃគូអភិវឌ្ឍន៍<br>រដ្ឋបាលថ្នាក់ក្រោមជាតិ | ៤០/ឆ្នាំ |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| ៣.៣.២ | ការសិក្សាស្ដីពីការវិភាគចំណាយ និងហិរញ្ញប្បទានរបស់កម្មវិធី | ចំនួនរបាយការណ៍ | | | x | | | | | ក.ជ.គ.ស. អ.យ.ក. ដៃគូអភិវឌ្ឍន៍ | ៨០ |
| ៣.៣.៣ | ជំរុញការកៀរគរឱ្យចូលរួមផ្ដល់សម្ភារៈ ថវិកា និងកម្លាំងពលកម្មពីសហគមន៍សម្រាប់គាំទ្រកម្មវិធីផ្ដល់អាហារតាមសាលារៀន | ធនធានសហគមន៍គាំទ្រកម្មវិធីផ្ដល់អាហារតាមសាលារៀន | x | x | x | x | x | x | x | អ.យ.ក. ម.ផ. ក.ធ.ស. | ២០០/ឆ្នាំ |
| ៣.៣.៤ | ជំរុញសហគមន៍ចូលរួមពិនិត្យតាមដានការអនុវត្តកម្មវិធីផ្ដល់អាហារតាមសាលារៀន | របាយការណ៍ពិនិត្យតាមដានរបស់ថ្នាក់ជាតិ ថ្នាក់ខេត្ត និងក្រុង ស្រុក បានបញ្ជាក់ពីការចូលរួមពិនិត្យរបស់សហគមន៍ក្នុងការអនុវត្តកម្មវិធី | x | x | x | x | x | x | x | អ.យ.ក. ក្រសួងស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញថ្នាក់ខេត្ត ថ្នាក់ក្រុង ស្រុក | – |
| យុទ្ធសាស្ត្រទី៣.៤៖ ពង្រីកកម្មវិធីផ្ដល់អាហារតាមសាលារៀនតាមលទ្ធភាព និងស្ថានភាពជាក់ស្ដែង | | | | | | | | | | | |
| ៣.៤.១ | ពង្រីកវិសាលភាពសាលារៀនអនុវត្តកម្មវិធីផ្ដល់អាហារតាមសាលារៀនស្របតាមយុទ្ធសាស្ត្ររួមស្ដីពីការផ្ទេរ-ទទួល | ចំនួនសាលារៀនបានពង្រីកស្របតាម យុទ្ធសាស្ត្ររួមស្ដីពីការផ្ទេរ-ទទួល | x | x | x | x | x | | | ក.ជ.គ.ស. អ.យ.ក. ដៃគូអភិវឌ្ឍន៍ | ៤០០០/ឆ្នាំ |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័ន ទទួលខុសត្រូវ | ថវិកា (លាន រៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| ៣.៤.២ | សិក្សាលទ្ធភាពពង្រីកសាលារៀនគោលដៅថ្មីផ្អែកតាមលក្ខណៈ វិនិច្ឆ័យ និងភាពទ្រទ្រង់បាននៃថវិកាជាតិ ឬលទ្ធភាពនៃការពង្រឹងគុណភាពអនុវត្តកម្មវិធី | បញ្ជីចំនួនសាលារៀនគោលដៅថ្មីគ្រោងពង្រីកត្រូវបានអនុម័ត | | | | | x | | | ក.ជ.គ.ស.<br>អ.យ.ក.<br>ស.ហ.វ.<br>ដៃគូអភិវឌ្ឍន៍ | ៤០ |
| ៣.៤.៣ | ជំរុញរដ្ឋបាលក្រុង ស្រុកគាំទ្រការផ្តល់អាហារតាមសាលារៀនក្នុងមូលដ្ឋានខ្លួន(មុខងារកាតព្វកិច្ចឬជម្រើស) | ចំនួនសាលារៀនថ្មីបានពង្រីកអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន | | | | | x | x | x | ម.ផ. | – |
| ៣.៤.៤ | ផ្តល់វគ្គបណ្តុះបណ្តាលស្តីពី ការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនដល់គោលដៅពង្រីកថ្មី និងអ្នកពាក់ព័ន្ធថ្នាក់ក្រោមជាតិ | របាយការណ៍វគ្គបណ្តុះបណ្តាល | | | x | x | x | x | x | អ.យ.ក.<br>ដៃគូអភិវឌ្ឍន៍ | ១២០ /ឆ្នាំ |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| ៣.៤.៥ | ជំរុញការចូលរួមរបស់សហគមន៍ជាសម្ភារៈ ថវិកា ក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ផ្ដល់គ្រឿងទេស អុស និងសម្ភារៈផ្ទះបាយសម្រាប់អនុវត្តកម្មវិធីដែលបានផ្ទេរ និងពង្រីកថ្មី | ចំនួនសាលារៀនដែលទទួលបានការចូលរួមគាំទ្រពីសហគមន៍ | x | x | x | x | x | x | x | អ.យ.ក.<br>ដៃគូអភិវឌ្ឍន៍ | – |
| យុទ្ធសាស្ត្រទី៣.៥៖ លើកកម្ពស់ការទទួលបានអាហារប្រកបដោយសមធម៌ និងបរិយាបន្ន | | | | | | | | | | | |
| ៣.៥.១ | សិក្សាវាយតម្លៃអំពីរបៀបរបបនិងចំណង់ចំណូលចិត្តនៃការហូបអាហាររបស់សិស្ស | របាយការណ៍នៃការសិក្សាអំពីរបៀបរបបនិងចំណង់ចំណូលចិត្តនៃការហូបអាហាររបស់សិស្ស | | | x | | | x | x | អ.យ.ក.<br>ដៃគូអភិវឌ្ឍន៍ | ៤០/ឆ្នាំ |
| ៣.៥.២ | រៀបចំមុខម្ហូបស្តង់ដាដែលអាចបរិភោគដល់កុមារ ដោយគិតគូរពីដល់បរិយាបន្ន | មុខម្ហូបស្តង់ដា បានរៀបចំប្រកបដោយបរិយាបន្ន | | | | x | | | | អ.យ.ក.<br>ស.ខ.<br>ក.ធ.ស.<br>ដៃគូអភិវឌ្ឍន៍ | ២០០ |

| | សកម្មភាព | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| ៣.៥.៣ | ជំរុញការបង្កើតបរិយាកាសមេត្រីសម្រាប់ការទទួលទានអាហារតាមសាលារៀន | ចំនួនសាលារៀនដែល បានអនុវត្តការផ្ដល់អាហារប្រកបដោយបរិយាកាសមេត្រី | | | x | x | x | x | x | អ.យ.ក.<br>គ.ជ.គ.ស.<br>ក.ធ.ស. | – |
| **យុទ្ធសាស្ត្រទី៤៖ លើកកម្ពស់សុខភាព និងអាហារូបត្ថម្ភ** | | | | | | | | | | | |
| យុទ្ធសាស្ត្រវង៤.១៖ អភិវឌ្ឍ និងអនុវត្តស្តង់ដាអាហារូបត្ថម្ភដោយផ្អែកលើបរិបទជាក់ស្តែង | | | | | | | | | | | |
| ៤.១.១ | រៀបចំស្តង់ដាអាហារូបត្ថម្ភសម្រាប់ក្រុមសិស្សគោលដៅ | ស្តង់ដាអាហារូបត្ថម្ភ សម្រាប់ក្រុមសិស្សគោលដៅត្រូវបានអនុម័ត | | | | x | | | | អ.យ.ក.<br>ស.ខ.<br>ក.ស.ក.<br>ដៃគូអភិវឌ្ឍន៍ | ២០០ |
| ៤.១.២ | រៀបចំសេចក្តីណែនាំ អនុវត្តស្តង់ដាអាហារូបត្ថម្ភ | សេចក្តីណែនាំអនុវត្តស្តង់ដាអាហារូបត្ថម្ភសម្រាប់អាហារតាមសាលារៀនត្រូវបានដាក់ឱ្យអនុវត្ត | | | | x | | | | អ.យ.ក.<br>ស.ខ.<br>ក.ស.ក. | ១០ |
| ៤.១.៣ | ផ្សព្វផ្សាយ និងជំរុញការអនុវត្តស្តង់ដាអាហារូបត្ថម្ភនិងផ្តល់អាហារតាមសាលារៀន | របាយការណ៍សាលារៀនអនុវត្តស្តង់ដាអាហារូបត្ថម្ភ | | | | | x | x | x | អ.យ.ក.<br>ស.ខ.<br>ក.ស.ក. | - |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| ៤.១.៤ | សិក្សាគំរូសាកល្បងការលាយអង្ករមីក្រូសារជាតិទៅក្នុងកម្មវិធីជាតិផ្តល់អាហារតាមសាលារៀន | ចំនួនសាលារៀនសាកល្បងបញ្ចូលអង្ករមីក្រូសារជាតិក្នុងកម្មវិធីផ្តល់អាហារតាមសាលារៀន | | | x | | | | | អ.យ.ក.<br>ផ.ក.<br>ក.ក.ជ.<br>ស.ខ.<br>ក.ស.ក.<br>ដៃគូអភិវឌ្ឍន៍ | ៤០០ |
| ៤.១.៥ | សិក្សាលទ្ធភាពនៃការប្រើប្រាស់អង្ករបញ្ចូលមីក្រូសារជាតិនៅក្នុងការផ្តល់អាហារតាមសាលារៀនគោលដៅប្រើប្រាស់ថវិកាជាតិ | របាយការសិក្សាពីលទ្ធភាពនៃការប្រើប្រាស់អង្ករបញ្ចូលមីក្រូសារជាតិក្នុងការផ្តល់អាហារតាមសាលារៀនគោលដៅ | | | | x | | | | អ.យ.ក.<br>ផ.ក.<br>ក.ស.ក.<br>ស.ខ.<br>ដៃគូអភិវឌ្ឍន៍ | - |
| ៤.១.៦ | ធ្វើបច្ចុប្បន្នកម្ម និងកែលម្អមុខងារប្រព័ន្ធព័ត៌មានគ្រប់គ្រងកម្មវិធីផ្តល់អាហារតាមសាលារៀន | ភាគរយសាលារៀនប្រើប្រាស់ប្រព័ន្ធទិន្នន័យបានត្រឹមត្រូវនិងទៀងទាត់ | | | x | | x | | | អ.យ.ក.<br>ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>ដៃគូអភិវឌ្ឍន៍ | ១០០ /ឆ្នាំ |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| ៤.១.៧ | ធ្វើបច្ចុប្បន្នកម្មសៀវភៅណែនាំប្រតិបត្តិ និងសម្ភារៈ ដោយផ្អែកលើគោលការណ៍ណែនាំស្ដីពីស្តង់ដាអាហារូបត្ថម្ភ | ចំនួនសៀវភៅ និងសម្ភារៈបានធ្វើបច្ចុប្បន្នភាពតាមប្រភេទ | | | | | x | | | អ.យ.ក.<br>ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>ដៃគូអភិវឌ្ឍន៍ | ២០០ |
| ៤.១.៨ | ផ្តល់វគ្គបណ្តុះបណ្តាល និងសម្ភារៈសម្រាប់ការប្រមូលទិន្នន័យសន្ទស្សន៍ម៉ាសរាងកាយតាមសាលារៀនគោលដៅ | ចំនួនសាលារៀនគោលដៅបានទទួលការគាំទ្រ | | x | | | | | | អ.យ.ក.<br>ដៃគូអភិវឌ្ឍន៍ | ១២០ |
| ៤.១.៩ | ប្រមូលទិន្នន័យសន្ទស្សន៍ម៉ាសរាងកាយតាមសាលារៀន | ទិន្នន័យស្ដីពីសន្ទស្សន៍ម៉ាសរាងកាយត្រូវបានប្រមូល និងរៀបចំវិភាគ | | x | x | x | x | x | x | អ.យ.ក.<br>ដៃគូអភិវឌ្ឍន៍ | – |
| ៤.១.១០ | ផ្ដល់ការប្រឹក្សាជាក្រុម ឬឯកជនដល់កុមារខ្វះអាហារូបត្ថម្ភ ប្រតិកម្មអាហារ និងទម្លាប់ហូបអាហារមិនប្រក្រតី | ភាគរយសាលារៀនបានផ្តល់ប្រឹក្សាដល់កុមារមានបញ្ហាសុខភាព | | | x | x | x | x | x | អ.យ.ក.<br>ស.ខ.<br>រដ្ឋបាលថ្នាក់ក្រោមជាតិ | ៤០/ឆ្នាំ |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| ៤.១.១១ | រៀបចំព្រឹត្តិការណ៍ និងសកម្មភាព លើកកម្ពស់ផ្សព្វផ្សាយអាហារូបត្ថម្ភល្អប្រសើរ និងការផ្លាស់ប្ដូរឥរិយាបថអាហារូបត្ថម្ភ | ភាគរយ សាលារៀនបានរៀបចំព្រឹត្តិការណ៍ និងសកម្មភាពផ្សេងៗលើកកម្ពស់ផ្សព្វផ្សាយអាហារូបត្ថម្ភល្អប្រសើរ និងការផ្លាស់ប្ដូរឥរិយាបថអាហារូបត្ថម្ភ | | x | x | x | x | x | x | អ.យ.ក. ក.ជ.គ.ស. ស.ឧ. រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ | ៦០/ឆ្នាំ |
| ៤.១.១២ | ផលិត និងចែកចាយមាតិកាឌីជីថល (ល្បែងកម្សាន្ត និងគំនូរជីវចល) ដើម្បីផ្សព្វផ្សាយការផ្លាស់ប្ដូរឥរិយាបថអាហារូបត្ថម្ភរបស់សិស្ស | ចំនួនមាតិកាឌីជីថលដែលបានបង្កើតនិងដាក់ឱ្យ ប្រើប្រាស់ | | | | | | | x | អ.យ.ក. ក.ជ.គ.ស. ស.ឧ. រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ | ១០០០ |
| ៤.១.១៣ | រៀបចំយុទ្ធសាស្ត្រជាតិស្ដីពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារលើកទី១ (២០២៥-២០៣០) | យុទ្ធសាស្ត្រជាតិស្ដីពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារលើកទី១ (២០២៥-២០៣០) ត្រូវអនុម័ត និងដាក់ឱ្យប្រើប្រាស់ | | | | x | | | | ក.ជ.អ.ជ. ផ.ក. ក្រសួង ស្ថាប័នពាក់ព័ន្ធ | ១២០ |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| ៤.១.១៤ | ជំរុញការផលិតនិងការប្រើប្រាស់អាហារបញ្ចូលមីក្រូសារជាតិ | របាយការណ៍ សហគ្រាស សាជីវកម្ម ក្រុមហ៊ុនផលិត ស្ដីពីការជំរុញការផលិតនិង ការប្រើប្រាស់អាហារបញ្ចូលមីក្រូសារជាតិ | | x | x | x | x | x | x | ក.ជ.អ.ជ.<br>ផ.ក.<br>ក្រសួង ស្ថាប័នពាក់ព័ន្ធ | ៤០/ឆ្នាំ |
| ៤.១.១៥ | បង្កើនការយល់ដឹងស្ដីពីសារៈសំខាន់នៃការប្រើប្រាស់អាហារបញ្ចូលមីក្រូសារជាតិតាមសាលារៀន | របាយការណ៍សិក្ខាសាលា ឬវគ្គបណ្ដុះបណ្ដាលស្ដីពីសារៈសំខាន់នៃការប្រើប្រាស់អាហារបញ្ចូលមីក្រូសារជាតិ តាមសាលារៀន | | | x | x | x | x | x | ផ.ក.<br>អ.យ.ក<br>ក្រសួង ស្ថាប័នពាក់ព័ន្ធ | ២០/ឆ្នាំ |
| ៤.១.១៦ | ជំរុញការអនុវត្តលិខិតបទដ្ឋានគតិយុត្ត ស្ដីពីអាហារបញ្ចូលមីក្រូសារជាតិ | របាយការណ៍សិក្ខាសាលា/វគ្គបណ្ដុះបណ្ដាលពង្រឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្ត ស្ដីពីអាហារបញ្ចូលមីក្រូសារជាតិ | | | x | x | x | x | x | ផ.ក.<br>អ.យ.ក. ក្រសួងស្ថាប័នពាក់ព័ន្ធ | ៣០/ឆ្នាំ |
| ៤.១.១៧ | ផ្សព្វផ្សាយអំពីយេនឌ័រ សុខភាព និងអាហារូបត្ថម្ភដល់ស្ត្រី និងក្មេងស្រី ប្រកបដោយគុណភាព ប្រសិទ្ធភាព និងបរិយាបន្ន។ | ចំនួនកម្មវិធីអប់រំ និងផ្សព្វផ្សាយអំពីយេនឌ័រ និងសុខភាព | x | x | x | x | x | x | x | ក.ន. | ២០០/ឆ្នាំ |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| យុទ្ធសាស្ត្រវង៤.២៖ ជំរុញអនុវត្តស្តង់ដាសុវត្ថិភាពម្ហូបអាហារ | | | | | | | | | | | |
| ៤.២.១ | រៀបចំនិងអនុម័តស្តង់ដាសុវត្ថិភាពម្ហូបអាហារតាមសាលារៀន | ស្តង់ដាសុវត្ថិភាពម្ហូបអាហារតាមសាលារៀន បានរៀបចំនិងអនុម័ត | | | | x | | | | អ.យ.ក. ស.ខ. ដៃគូអភិវឌ្ឍន៍ ក្រសួង ស្ថាប័នពាក់ព័ន្ធ | ៨០ |
| ៤.២.២ | ពង្រឹងសមត្ថភាពចុងភៅតាមសាលារៀនស្តីពីការចម្អិនអាហារប្រកបដោយសុវត្ថិភាពតាមសាលារៀន | ចំនួនចុងភៅសាលារៀនទទួលបានការបណ្តុះបណ្តាលតាមភេទ | | | | | x | x | x | អ.យ.ក. ស.ខ. ម.ផ. ដៃគូអភិវឌ្ឍន៍ | ២០០/ឆ្នាំ |
| ៤.២.៣ | ផ្សព្វផ្សាយអនាម័យ និងស្តង់ដាសុវត្ថិភាពម្ហូបអាហារតាមរយៈ បុព្វជិតសាសនា និងតាមវិធីសាស្ត្រផ្សេងៗក្នុងការអនុវត្តកម្មវិធី | ការផ្សព្វផ្សាយស្តីពីការអនុវត្តកម្មវិធី និងសុវត្ថិភាពម្ហូបអាហារដោយបុព្វជិតសាសនា | x | x | x | x | x | x | x | ក.ធ.ស. អ.យ.ក. ស.ខ. ម.ផ. ដៃគូអភិវឌ្ឍន៍ | ៤០/ឆ្នាំ |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| ៤.២.៤ | រៀបចំគោលការណ៍ប្រតិបត្តិស្ដីពីយន្តការអន្តរាគមន៍សង្គ្រោះបន្ទាន់ឆ្លើយតបទៅនឹងបញ្ហាពុលអាហារតាមសាលារៀន | គោលការណ៍ប្រតិបត្តិ ស្ដីពីការអន្តរាគមន៍សង្គ្រោះបន្ទាន់ឆ្លើយតបបញ្ហាពុលអាហារបានអនុម័ត និងដាក់ឱ្យប្រើប្រាស់ | | | | x | | x | x | អ.យ.ក. ស.ខ. ក្រសួងស្ថាប័នពាក់ព័ន្ធ | ៨០/ឆ្នាំ |
| ៤.២.៥ | រៀបចំគោលការណ៍ណែនាំស្ដីពីសុវត្ថិភាពនិងគុណភាពនៃផលិតកម្ម ដើម្បីលើកកម្ពស់សុវត្ថិភាពស្បៀង ក្នុងខ្សែប្រវាក់ផ្គត់ផ្គង់នៅក្នុងកម្មវិធីផ្ដល់អាហារតាមសាលារៀន | គោលការណ៍ណែនាំស្ដីពីសុវត្ថិភាពនិងគុណភាពនៃផលិតកម្ម ដើម្បីលើកកម្ពស់សុវត្ថិភាពស្បៀង ក្នុងខ្សែប្រវាក់ផ្គត់ផ្គង់បានរៀបចំនិងផ្សព្វផ្សាយ | | | x | | | | | ក.ស.ក. អ.យ.ក. រដ្ឋបាលថ្នាក់ក្រោមជាតិ | ៤០ |
| ៤.២.៦ | រៀបចំបែបបទ អនុវត្តប្រព័ន្ធធានាសុវត្ថិភាពម្ហូបអាហារសម្រាប់ការផ្ដល់អាហារតាមសាលារៀន កំណត់ហានិភ័យ បង្ការ គ្រប់គ្រង និងតាមដានបញ្ហាទាក់ទងនឹងសុវត្ថិភាពម្ហូបអាហារ ធានាការបញ្ចូលក្នុងផែនការតាមវិស័យ | សេចក្ដីណែនាំស្ដីពីការអនុវត្តប្រព័ន្ធធានាសុវត្ថិភាពម្ហូបអាហារត្រូវតាមសាលារៀនបានអនុម័ត | | | | x | | | | អ.យ.ក. ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ | ៤០ |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័ន ទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| យុទ្ធសាស្ត្រវង៤.៣៖ ជំរុញការធ្វើពិពិធកម្មមុខម្ហូបសម្រាប់កម្មវិធី ជានាផ្សារភ្ជាប់កម្មវិធីផ្តល់អាហារតាមសាលារៀនជាមួយនឹងកម្មវិធីសិក្សាអប់រំសុខភាព និងអាហារូបត្ថម្ភ | | | | | | | | | | | |
| ៤.៣.១ | ប្រើប្រាស់បច្ចេកវិទ្យាក្នុងការរៀបចំបញ្ជីមុខម្ហូបមេត្រីសម្រាប់កុមារ | ឧបករណ៍បច្ចេកវិទ្យាសម្រាប់រៀបចំបញ្ជីមុខម្ហូបដែលមានមេត្រីសម្រាប់កុមារ បានបង្កើតនិងប្រើប្រាស់តាមសាលារៀន | | | | x | | | | អ.យ.ក. ដៃគូអភិវឌ្ឍន៍ | ២០០ |
| ៤.៣.២ | បង្កើតឧបករណ៍គណនាតម្លៃអាហារូបត្ថម្ភសម្រាប់រៀបចំមុខម្ហូបមេត្រីដល់កុមារ | ឧបករណ៍គណនាតម្លៃអាហារូបត្ថម្ភបានបង្កើតនិងដាក់ឱ្យប្រើប្រាស់ | | | | x | | | | អ.យ.ក. ដៃគូអភិវឌ្ឍន៍ | ១០០ |
| ៤.៣.៣ | អភិវឌ្ឍសមត្ថភាពមន្ត្រីបង្គោលថ្នាក់ជាតិ ថ្នាក់ខេត្ត ក្រុង ស្រុក និងសាលារៀនលើការប្រើប្រាស់បច្ចេកវិទ្យានិងឧបករណ៍សម្រាប់រៀបចំបញ្ជីមុខម្ហូប | ចំនួនមន្ត្រីបង្គោលថ្នាក់ជាតិ ថ្នាក់ខេត្ត ក្រុង ស្រុក និងសាលារៀនទទួលបានការបណ្តុះបណ្តាល | | | | x | x | | | អ.យ.ក. | ២០០ /ឆ្នាំ |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័ន ទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| ៤.៣.៤ | ជំរុញ និងគាំទ្រលើកាផ្សព្វផ្សាយស្តីពីសុខភាព និងអនាម័យដល់ស្ត្រី និងកុមារនៅតំបន់មានការផ្តល់អាហារតាមសាលារៀន | របាយការណ៍ពីវឌ្ឍនភាពការងារគាំទ្រលើសុខភាព និងអនាម័យដល់ស្ត្រី និងកុមារ | x | x | x | x | x | x | x | អ.យ.ក.<br>ក.ធ.ស.<br>ស.ខ.<br>ម.ផ. | ២០/ឆ្នាំ |
| យុទ្ធសាស្ត្រវង៤.៤៖ អភិវឌ្ឍ និងធានាការថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ព្រមទាំងសម្ភារៈចាំបាច់សម្រាប់ដំណើរការកម្មវិធី | | | | | | | | | | | |
| ៤.៤.១ | រៀបចំផែនការរយៈពេលមធ្យមកសាង ជួសជុលហេដ្ឋារចនាសម្ព័ន្ធគាំទ្រកម្មវិធីផ្តល់អាហារតាមសាលារៀន | ផែនការថវិកាគាំទ្រការសាងសង់ហេដ្ឋារចនាសម្ព័ន្ធបានអនុម័ត | | | x | | | | | អ.យ.ក.<br>ក្រសួង ស្ថាប័នពាក់ព័ន្ធ | – |
| ៤.៤.២ | សម្របសម្រួលការកសាងនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធគាំទ្រការចម្អិនឆ្លើយតបនឹងសុខភាព និងបរិស្ថាន | ហេដ្ឋារចនាសម្ព័ន្ធគាំទ្រការចម្អិននៅតាមសាលារៀនត្រូវបានសាងសង់និងកែលម្អ | | | x | x | x | x | x | ក.ជ.គ.ស.<br>អ.យ.ក.<br>ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>ដៃគូអភិវឌ្ឍន៍ | ៩០០/ឆ្នាំ |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| ៤.៤.៣ | ផ្តល់បរិក្ខារ និងសម្ភារៈប្រើប្រាស់ក្នុងផ្ទះបាយចាំបាច់ សម្រាប់កម្មវិធីផ្តល់អាហារតាមសាលារៀន | ចំនួនសាលារៀនដែលមានបរិក្ខារ និងសម្ភារៈចាំបាច់ប្រើប្រាស់ក្នុងផ្ទះបាយគ្រប់គ្រាន់ | | x | x | x | x | x | x | ក.ជ.គ.ស.<br>អ.យ.ក<br>ដៃគូអភិវឌ្ឍន៍ | ៤៥០/ឆ្នាំ |
| ៤.៤.៤ | ធ្វើបច្ចុប្បន្នកម្មគំនូសប្លង់ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ឆ្លើយតបនឹងបម្រែបម្រួលអាកាសធាតុ | ប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់គំនូសប្លង់ ស្តីពីហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ឆ្លើយតបនឹងបម្រែបម្រួលអាកាសធាតុតាមសាលារៀន | | | | x | | | | អ.យ.ក.<br>ដៃគូអភិវឌ្ឍន៍ | ២០ |
| ៤.៤.៥ | ជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញលើការចម្អិនអាហារតាមសាលារៀន | ចំនួនសាលារៀនដែលបានប្រើប្រាស់ថាមពលកកើតឡើងវិញសម្រាប់ប្រើប្រាស់ក្នុងការចម្អិនអាហារ | | | x | x | x | x | x | អ.យ.ក.<br>ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>ដៃគូអភិវឌ្ឍន៍ | ៦០/ឆ្នាំ |
| ៤.៤.៦ | ជំរុញ និងលើកទឹកចិត្តសាលារៀនគោលដៅអនុវត្តការចម្អិនអាហារដោយថាមពលកកើតឡើងវិញ | ចំនួនសាលារៀនគោលដៅអនុវត្តការចម្អិនអាហារប្រើប្រាស់ថាមពលកកើតឡើងវិញ | | | | x | x | x | x | អ.យ.ក.<br>ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>ដៃគូអភិវឌ្ឍន៍ | ៦០/ឆ្នាំ |

| | សកម្មភាព | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| **យុទ្ធសាស្ត្រទី៥៖ ជំរុញការអភិវឌ្ឍកសិកម្ម និងសេដ្ឋកិច្ចក្នុងសហគមន៍** | | | | | | | | | | | |
| យុទ្ធសាស្ត្រវង៥.១៖ លើកកម្ពស់ការយល់ដឹងដល់អ្នកផ្គត់ផ្គង់ ឬកសិករក្នុងសហគមន៍អំពីតម្រូវការ ស្បៀងផ្គត់ផ្គង់ដល់កម្មវិធីផ្ដល់អាហារតាមសាលារៀន | | | | | | | | | | | |
| ៥.១.១ | ជំរុញសហគមន៍កសិកម្ម ឬ សហគមន៍កសិកម្មទំនើប អ្នកផលិត និងពាណិជ្ជករ ចូលរួម ក្នុងការផ្គត់ផ្គង់ស្បៀង | ភាគរយនៃសហគមន៍កសិកម្មជាអ្នកផ្គត់ផ្គង់ស្បៀង | | X | X | X | X | X | X | អ.យ.ក.<br>ក.ស.ក. | – |
| ៥.១.២ | ផ្សព្វផ្សាយពីគោលការណ៍ នីតិវិធីនៃការជ្រើសរើសអ្នកផ្គត់ផ្គង់ជូន ដល់សហគមន៍ កសិកម្ម និងសហគមន៍កសិកម្មទំនើប និងក្រុមអ្នកផលិត | របាយការណ៍ផ្សព្វផ្សាយ | X | X | X | X | X | X | X | អ.យ.ក.<br>ក.ស.ក.<br>រដ្ឋបាលថ្នាក់ក្រោមជាតិ<br>ដៃគូអភិវឌ្ឍន៍ | – |
| ៥.១.៣ | ប្រើប្រាស់ប្រព័ន្ធតាមដានតម្លៃទីផ្សារស្បៀងជាមូលដ្ឋានក្នុងការកំណត់តម្លៃគោល | ប្រព័ន្ធតាមដានតម្លៃទីផ្សារស្បៀង បានបង្កើត និងដំណើរការ (តាមប្រព័ន្ធបច្ចេកវិទ្យា) | X | X | X | X | X | X | X | ក.ស.ក.<br>អ.យ.ក. រដ្ឋបាលថ្នាក់ក្រោមជាតិ<br>ដៃគូអភិវឌ្ឍន៍ | ២០០/ឆ្នាំ |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| ៥.១.៤ | ចែករំលែកព័ត៌មានទីផ្សារនិងតម្លៃស្បៀងជាមួយអ្នកពាក់ព័ន្ធ | របាយការព័ត៌មានទីផ្សារនិងតម្លៃកសិផលបានចែករំលែកជាមួយអ្នកពាក់ព័ន្ធ | | x | x | x | x | x | x | ក.ស.ក.<br>រដ្ឋបាលថ្នាក់ក្រោមជាតិ<br>ដៃគូអភិវឌ្ឍន៍ | – |
| ៥.១.៥ | បង្កើត និងដំណើរការប្រព័ន្ធទិន្នន័យទាន់ពេលផ្សារភ្ជាប់ជាមួយអ្នកផ្គត់ផ្គង់និងកម្មវិធី | ទិន្នន័យងាយស្រួលរកនិងទាន់ពេលស្តីពីកម្មវិធីផ្តល់អាហារតាមសាលារៀន | x | x | x | | | | | ក.ស.ក.<br>អ.យ.ក.<br>ដៃគូអភិវឌ្ឍន៍ | ១២០ |
| ៥.១.៦ | រៀបចំកិច្ចសន្ទនាតភ្ជាប់ទីផ្សារ (កិច្ចសន្យាកសិកម្ម) ដើម្បីបង្កើនការចូលរួមរបស់អ្នកពាក់ព័ន្ធ ក្នុងកម្មវិធីផ្តល់អាហារតាមសាលារៀន | ចំនួនដងនៃ កិច្ចសន្ទនាតភ្ជាប់ទីផ្សារបានរៀបចំ និងអនុវត្ត | x | x | x | x | x | x | x | ក.ស.ក.<br>អ.យ.ក.<br>រដ្ឋបាលថ្នាក់ក្រោមជាតិ | ១០០/ឆ្នាំ |
| ៥.១.៧ | ពិនិត្យមើលខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងកម្មវិធីផ្តល់អាហារតាមសាលារៀន | ចំនួនសាលារៀនបានពិនិត្យមើលខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងកម្មវិធីផ្តល់អាហារតាមសាលារៀន | | x | x | x | x | x | x | ក.ស.ក.<br>អ.យ.ក.<br>ដៃគូអភិវឌ្ឍន៍ | ៤០/ឆ្នាំ |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័ន ទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| ៥.១.៨ | ជំរុញការប្រើប្រាស់ ផលិតផលក្នុងសហគមន៍ពីសហគមន៍កសិកម្ម ឬសហគមន៍កសិកម្មទំនើប ឬក្រុមផលិតក្នុងមូលដ្ឋាន | បរិមាណស្បៀងផ្គត់ផ្គង់ដែលបានទិញ (គិតជាតោន) ពីសហគមន៍កសិកម្ម ឬសហគមន៍កសិកម្មទំនើប ឬក្រុមផលិត | x | x | x | x | x | x | x | អ.យ.ក. ក.ស.ក. ដៃគូអភិវឌ្ឍន៍ អ្នកផលិត អ្នកផ្គត់ផ្គង់ | ៤០/ឆ្នាំ |
| យុទ្ធសាស្ត្រវង៥.២៖ ចងក្រងសហគមន៍ដើម្បីផ្គត់ផ្គង់កសិផលដល់កម្មវិធីផ្តល់អាហារតាមសាលារៀន | | | | | | | | | | | |
| ៥.២.១ | រៀបចំផែនការសកម្មភាពស្វែងរកការគាំទ្រពីក្រសួង ស្ថាប័នសំខាន់ៗ និងអ្នកពាក់ព័ន្ធ លើការកៀរគរកសិករ និងសហគមន៍ឱ្យផ្គត់ផ្គង់ស្បៀងដល់សាលារៀន | ផែនការសកម្មភាពស្វែងរកការគាំទ្រពីក្រសួង ស្ថាប័នសំខាន់ៗនិងអ្នកពាក់ព័ន្ធបានរៀបចំ | x | x | x | x | x | x | x | ក.ស.ក. អ.យ.ក. រដ្ឋបាលថ្នាក់ក្រោមជាតិ | ២០/ឆ្នាំ |
| ៥.២.២ | ចងក្រង និងពង្រឹងសហគមន៍កសិកម្មទំនើប សហគមន៍កសិកម្ម និងក្រុមផលិត ដើម្បីផ្គត់ផ្គង់កសិផលដល់សាលារៀន | ចំនួនសហគមន៍កសិកម្មទំនើប សហគមន៍កសិកម្ម និងក្រុមផលិតបានផ្គត់ផ្គង់ស្បៀងដល់សាលារៀន | x | x | x | x | x | x | x | ក.ស.ក. | ៦១៥/ឆ្នាំ |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| ៥.២.៣ | បណ្ដុះបណ្ដាល សហគមន៍ និងក្រុម ផលិតពីវិធីដាំដុះស្របតាមស្តង់ដាអនុវត្តកសិកម្មល្អ | សហគមន៍ និងក្រុម ផលិតទទួលការបណ្ដុះបណ្ដាលស្ដីពីវិធីដាំដុះស្របតាមស្តង់ដាអនុវត្តកសិកម្មល្អ | x | x | x | x | x | x | x | ក.ស.ក. ដៃគូអភិវឌ្ឍន៍ | ៤០/ឆ្នាំ |
| ៥.២.៤ | បណ្ដុះបណ្ដាលសហគមន៍កសិកម្ម និងអ្នកផលិតនិងសមាជិកសហគមន៍ផ្សេងទៀតស្ដីពីឱកាសទីផ្សារនៃកម្មវិធីផ្ដល់អាហារតាមសាលារៀន | ចំនួនសហគមន៍កសិកម្ម ទទួលបានការបណ្ដុះបណ្ដាល | x | x | x | x | x | x | x | ក.ស.ក. អ.ឃ.ក. | ៤០/ឆ្នាំ |
| ៥.២.៥ | ពង្រឹងសមត្ថភាពសហគមន៍កសិកម្ម និងអ្នកផលិតស្ដីពីការអនុវត្តកសិកម្ម ការកែច្នៃនិងថែរក្សាអាហារ សុវត្ថិភាពនិងគុណភាពអាហារ | ចំនួនវគ្គបណ្ដុះបណ្ដាលស្ដីពីការអនុវត្តកសិកម្ម ការកែច្នៃនិងថែរក្សាអាហារ សុវត្ថិភាពនិងគុណភាពអាហារ | x | x | x | x | x | x | x | ក.ស.ក. ដៃគូអភិវឌ្ឍន៍ | ១០០/ឆ្នាំ |
| ៥.២.៦ | ផ្សារភ្ជាប់ការចុះត្រួតពិនិត្យតាមដានស្ដីពីសុវត្ថិភាព | ចំនួនការត្រួតពិនិត្យរបស់មន្ត្រីកសិកម្មឃុំ ពីសុវត្ថិភាពកសិផល | x | x | x | x | x | x | x | ក.ស.ក. | ១៣០/ឆ្នាំ |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| | កសិផលដែលដាំដុះដោយសហគមន៍ និងក្រុមផលិតដោយមន្ត្រីកសិកម្មឃុំសម្រាប់កម្មវិធីផ្តល់អាហារតាមសាលារៀន | ដាំដុះដោយសហគមន៍ និងក្រុមផលិត | | | | | | | | | |
| យុទ្ធសាស្ត្រវង៥.៣៖ អភិវឌ្ឍនិងពង្រឹងការអនុវត្តនីតិវិធីការជ្រើសរើសអ្នកផ្គត់ផ្គង់ក្នុងសហគមន៍ | | | | | | | | | | | |
| ៥.៣.១ | សាកល្បងអនុវត្តគំរូនៃការជ្រើសរើសអ្នកផ្គត់ផ្គង់មានភាពបត់បែន | ចំនួនការសិក្សា បានរៀបចំ | | | x | x | x | x | x | អ.យ.ក.<br>ក.ស.ក.<br>ស.ខ.<br>រដ្ឋបាលថ្នាក់ក្រោមជាតិ<br>ដៃគូអភិវឌ្ឍន៍ | ៤០ |
| ៥.៣.២ | សិក្សាពីគំរូ ការជ្រើសរើសអ្នកផ្គត់ផ្គង់ | របាយការណ៍សិក្សាពីគំរូនៃការជ្រើសរើសអ្នកផ្គត់ផ្គង់ដែលជួយបង្កើនការអភិវឌ្ឍន៍កសិកម្មនិងសេដ្ឋកិច្ចមូលដ្ឋានបានរៀបចំ | | | x | | | | | អ.យ.ក.<br>ក.ស.ក.<br>ដៃគូអភិវឌ្ឍន៍ | ៤០០ |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| ៥.៣.៣ | ពិនិត្យឡើងវិញ លើនីតិវិធីនិងដំណើរការនៃការជ្រើសរើសអ្នកផ្គត់ផ្គង់ | នីតិវិធីជ្រើសរើសអ្នកផ្គត់ផ្គង់បានធ្វើបច្ចុប្បន្នភាពដែលមានលក្ខណៈបត់បែន ស្របតាមស្ថានភាពសេដ្ឋកិច្ចនិងផលិតផលក្នុងស្រុក | | | | | x | | | អ.យ.ក. ដៃគូអភិវឌ្ឍន៍ រដ្ឋបាលថ្នាក់ក្រោមជាតិ | ៨០ |
| ៥.៣.៤ | ពិនិត្យលទ្ធភាព កែសម្រួលប្រព័ន្ធព័ត៌មានគ្រប់គ្រងកម្មវិធីលើមុខងារជ្រើសរើសអ្នកផ្គត់ផ្គង់តាមបច្ចេកវិទ្យា | ប្រព័ន្ធព័តមានគ្រប់គ្រងទិន្នន័យបានធ្វើឱ្យទំនើប និងដាក់ឱ្យប្រើប្រាស់ | | | | | x | | | អ.យ.ក. ដៃគូអភិវឌ្ឍន៍ រដ្ឋបាលថ្នាក់ក្រោមជាតិ | ៨០ |
| ៥.៣.៥ | ជំរុញការពិនិត្យតាមដានប្រភពស្បៀងផ្គត់ផ្គង់ក្នុងកម្មវិធីផ្តល់អាហារតាមសាលារៀន | របាយការណ៍ពិនិត្យតាមដានប្រភពស្បៀង | x | x | x | x | x | x | x | អ.យ.ក. រដ្ឋបាលថ្នាក់ក្រោមជាតិ | ៤០/ឆ្នាំ |
| យុទ្ធសាស្ត្ររង៥.៤៖ បណ្តុះស្មារតីសិស្ស និងសហគមន៍ឱ្យស្រឡាញ់ និងផ្តល់តម្លៃអាហារដែលប្រើប្រាស់កសិផលក្នុងសហគមន៍ | | | | | | | | | | | |
| ៥.៤.១ | ជំរុញសាលារៀនអនុវត្តកម្មវិធីរៀបចំ សួនកសិកម្ម ផ្សារភ្ជាប់នឹងមុខវិជ្ជាបំណិនជីវិត | ភាគរយសាលារៀនអនុវត្តកម្មវិធីមានសួនកសិកម្ម | x | x | x | x | x | x | x | អ.យ.ក. ក.ស.ក. រដ្ឋបាល ថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ | ២០០/ឆ្នាំ |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| ៥.៤.២ | ជំរុញសាលារៀនបង្ហាញការចម្អិនអាហារ ដោយប្រើប្រាស់កសិផលសហគមន៍ ផ្សារភ្ជាប់សារៈសំខាន់អាហារចំពោះសុខភាព | ភាគរយសាលារៀនបង្ហាញការចម្អិនអាហារប្រើផលិតផលសហគមន៍ | x | x | x | x | x | x | x | អ.យ.ក. រដ្ឋបាលថ្នាក់ក្រោមជាតិ | ៨០/ឆ្នាំ |
| ៥.៤.៣ | ជំរុញសាលារៀននាំសិស្សទៅធ្វើទស្សនៈកិច្ចសិក្សាតាមចម្ការដំណាំ ដើម្បីរៀនសូត្រពីការអនុវត្តការដាំដុះប្រកបដោយសុវត្ថិភាព | ភាគរយសាលារៀនបានរៀបចំទស្សនៈកិច្ចសិក្សាតាមចម្ការ | | | x | x | x | x | x | អ.យ.ក. រដ្ឋបាលថ្នាក់ក្រោមជាតិ | – |
| ៥.៤.៤ | រៀបចំព្រឹត្តិការណ៍តាំងពិពណ៌ការប្រកួតប្រជែងស្នាដៃសិស្សនៅកម្រិតសាលារៀនស្តីពីផ្តល់តម្លៃអាហារមានប្រភពពីផលិតផលក្នុងមូលដ្ឋាន | ភាគរយសាលារៀនបានរៀបចំព្រឹត្តិការណ៍ | | | x | x | x | x | x | អ.យ.ក. រដ្ឋបាលថ្នាក់ក្រោមជាតិ | ៤០/ឆ្នាំ |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| **យុទ្ធសាស្ត្រទី៦៖ ពង្រឹងអភិបាលកិច្ច ភាពជាដៃគូ និងការសម្របសម្រួលអន្តរវិស័យ** | | | | | | | | | | | |
| យុទ្ធសាស្ត្ររង៦.១៖ ផ្សារភ្ជាប់គោលនយោបាយវិស័យពាក់ព័ន្ធនានាជាមួយនឹងកម្មវិធីផ្តល់អាហារតាមសាលារៀន | | | | | | | | | | | |
| ៦.១.១ | ដាក់បញ្ចូលកម្មវិធីផ្តល់អាហារតាមសាលារៀនក្នុងផែនការរយៈពេលខ្លី មធ្យម និងវែងរបស់ក្រសួង និងស្ថាប័នពាក់ព័ន្ធ | កម្មវិធីផ្តល់អាហារតាមសាលារៀនមានរំលេចក្នុងផែនការរយៈពេលខ្លី មធ្យម និងវែង របស់ក្រសួងនិងស្ថាប័នពាក់ព័ន្ធ | x | x | x | x | x | x | x | អ.យ.ក. ស.ហ.វ. ក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ | – |
| ៦.១.២ | ពង្រឹងការអនុវត្តភារកិច្ចរបស់គណៈកម្មការដឹកនាំ និងគ្រប់គ្រងការអនុវត្តកម្មវិធីគ្រប់កម្រិតថ្នាក់ | របាយការណ៍កិច្ចប្រជុំរបស់គណៈកម្មការដឹកនាំនិងគ្រប់គ្រងការអនុវត្តកម្មវិធី | | x | x | x | x | x | x | គណៈកម្មការដឹកនាំនិងគ្រប់គ្រងកម្មវិធីគ្រប់កម្រិត | – |
| យុទ្ធសាស្ត្ររង៦.២៖ វិភាជថវិកាគាំទ្រកម្មវិធីផ្តល់អាហារតាមសាលារៀនឱ្យបានសមស្រប | | | | | | | | | | | |
| ៦.២.១ | កែសម្រួលរបបអាហារសិស្សដោយផ្អែកលើភស្តុតាងពីការស្រាវជ្រាវនានា | របាយការណ៍នៃការសិក្សាពីការស្រាវជ្រាវនានាត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការកំណត់របបអាហារសិស្ស | | | | | | | x | ក.ជ.គ.ស. ស.ហ.វ. អ.យ.ក. | – |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| ៦.២.២ | ពង្រឹងសមត្ថភាពការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចល្អ សម្រាប់អ្នកពាក់ព័ន្ធនៅថ្នាក់ជាតិនិងក្រោមជាតិ | អ្នកចូលរួមថ្នាក់ជាតិ និងក្រោមជាតិទទួលបានការបណ្ដុះបណ្ដាល | | | x | x | x | x | x | ស.ហ.វ.<br>ក.ជ.គ.ស.<br>អ.យ.ក. | ៤០/ឆ្នាំ |
| ៦.២.៣ | បង្កើតយន្តការផ្ដល់ព័ត៌មានត្រឡប់ ការចូលរួមយោបល់និងប្ដឹងតវ៉ា លើការអនុវត្តកម្មវិធីអាហារតាមសាលារៀន | យន្តការនិងនីតិវិធីនៃការប្ដឹងការតវ៉ាបានរៀបចំនិងដាក់ឱ្យដំណើរការ | | | | x | | | | ក.ជ.គ.ស.<br>អ.យ.ក.<br>ម.ផ. | ៤០ |
| យុទ្ធសាស្ត្រវង់៦.៣៖ អភិវឌ្ឍធនធានមនុស្សលើផ្នែកបច្ចេកវិទ្យាព័ត៌មានសម្រាប់ គ្រប់គ្រង និងអនុវត្តកម្មវិធីផ្ដល់អាហារតាមសាលារៀន | | | | | | | | | | | |
| ៦.៣.១ | ផ្ទេរប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្មវិធីផ្ដល់អាហារតាមសាលារៀន ជូនក្រសួងអប់រំ យុវជននិងកីឡា | ប្រព័ន្ធគ្រប់គ្រងទិន្នន័យបានផ្ទេរនិងគ្រប់គ្រងដោយក្រសួងអប់រំយុវជននិងកីឡា | | x | | | | | | អ.យ.ក. | - |

| សកម្មភាព | | សូចនាករ | ក្របខណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| ៦.៣.២ | ពង្រឹងសមត្ថភាពមន្ត្រីទទួលបន្ទុក និងអ្នកពាក់ព័ន្ធលើការប្រើប្រាស់ថែទាំ និងគ្រប់គ្រងប្រព័ន្ធគ្រប់គ្រងទិន្នន័យអាហារតាមសាលារៀន | ប្រព័ន្ធគ្រប់គ្រងទិន្នន័យអាហារតាមសាលារៀនមានដំណើរការជាប្រចាំ | x | x | x | x | x | x | x | អ.យ.ក. | ៥០/ឆ្នាំ |
| ៦.៣.៣ | អភិវឌ្ឍសមត្ថភាពស្តីពីការវិភាគទិន្នន័យ របាយការណ៍ ជូនក្រសួង ស្ថាប័នពាក់ព័ន្ធ | ចំនួនមន្ត្រីទទួលបន្ទុកបានទទួលការបណ្តុះបណ្តាល | | | x | | x | | | អ.យ.ក.<br>ក.ជ.គ.ស. | – |
| យុទ្ធសាស្ត្រទី៦.៤៖ ពង្រឹងយន្តការសម្របសម្រួលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងនិងអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន | | | | | | | | | | | |
| ៦.៤.១ | ពិនិត្យឡើងវិញយន្តការប្រព័ន្ធដើម្បីលទ្ធផលអប់រំកាន់តែប្រសើរនៃកម្មវិធីផ្តល់អាហារតាមសាលារៀនដើម្បីពិនិត្យលើការអភិវឌ្ឍសមត្ថភាពជាតិ | របាយការណ៍ស្តីពីយន្តការប្រព័ន្ធដើម្បីលទ្ធផលអប់រំកាន់តែប្រសើរនៃកម្មវិធីផ្តល់អាហារតាមសាលារៀន | | | x | | | | x | អ.យ.ក.<br>ក.ជ.គ.ស. | ៨០/ឆ្នាំ |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| ៦.៤.២ | ចែករំលែកឧត្តមានុវត្តន៍នៃការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនតាមរយៈការរៀបចំឬចូលរួមក្នុងវេទិកាថ្នាក់ជាតិ តំបន់ ឬសកល | ការចូលរួមវេទិកាថ្នាក់ជាតិ ថ្នាក់តំបន់ ឬសកលស្តីពីកម្មវិធីផ្តល់អាហារតាមសាលារៀន | x | x | x | x | x | x | x | អ.យ.ក. ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ | ១២០ /ឆ្នាំ |
| ៦.៤.៣ | ប្រជុំប្រចាំត្រីមាសរបស់គណៈកម្មការដឹកនាំ និគ្រប់គ្រងចំពោះកិច្ចការអនុវត្តកម្មវិធីថ្នាក់ខេត្ត និងស្រុក ក្រុង ឱ្យបានទៀងទាត់ | របាយការណ៍កិច្ចប្រជុំរបស់គណៈកម្មការដឹកនាំនិងគ្រប់គ្រង | | x | x | x | x | x | x | គ្រប់មន្ទីរពាក់ព័ន្ធ | - |
| យុទ្ធសាស្ត្រទី៦.៥៖ លើកកម្ពស់ការចូលរួមទៀងទាត់និងសកម្មពីដៃគូអភិវឌ្ឍន៍ វិស័យឯកជន សប្បុរសជន និងសហគមន៍ក្នុងការគាំទ្របច្ចេកទេស សម្ភារៈ ឬហិរញ្ញវត្ថុដល់កម្មវិធីផ្តល់អាហារតាមសាលារៀន | | | | | | | | | | | |
| ៦.៥.១ | រៀបចំមគ្គទេសក៍ស្តីពីការលើកកម្ពស់ភាពជាដៃគូ សម្រាប់គាំទ្រ និងធានានិរន្តរភាពកម្មវិធីផ្តល់អាហារតាមសាលារៀន | មគ្គទេសក៍នៃភាពជាដៃគូដើម្បីកៀរគរធនធានពីវិស័យឯកជនបានរៀបចំនិងដាក់ឱ្យប្រើប្រាស់ | | | x | | | | | អ.យ.ក. ក្រសួង ស្ថាប័នពាក់ព័ន្ធ | ៤០ |

| សកម្មភាព | | សូចនាករ | ក្របខណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| ៦.៥.២ | រៀបចំយុទ្ធនាការកៀរគរធនធានសម្រាប់ធានានិរន្តរភាពកម្មវិធីផ្តល់អាហារតាមសាលារៀន | យុទ្ធនាការកៀរគរធនធានគាំទ្រការផ្តល់អាហារតាមសាលារៀនត្រូវបានរៀបចំ និងមានដំណើរការជាប្រចាំ | | x | x | x | x | x | x | អ.យ.ក. | ២០/ឆ្នាំ |
| ៦.៥.៣ | រៀបចំរបាយការណ៍ស្តីពីការកំណត់ផែនទីភាគីពាក់ព័ន្ធ ដើម្បីយល់ពីសកម្មភាព និងផ្នែក មានសក្តានុពលគាំទ្រដល់ការផ្តល់អាហារតាមសាលារៀន | របាយការណ៍ស្តីពីការកំណត់ផែនទីភាគីពាក់ព័ន្ធត្រូវ បានរៀបចំ | | | | x | | | | ក.ជ.គ.ស.<br>អ.យ.ក. | ១២០ |
| ៦.៥.៤ | រៀបយុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មានពីការផ្តល់អាហារតាមសាលារៀន | យុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មានពីការផ្តល់អាហារតាមសាលារៀនបានរៀបចំ | | | | | x | | | អ.យ.ក.<br>ក.ជ.គ.ស<br>ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>រដ្ឋបាលថ្នាក់ក្រោមជាតិ | ៤០ |

| សកម្មភាព | | សូចនាករ | ក្របខ័ណ្ឌពេលវេលា | | | | | | | ស្ថាប័នទទួលខុសត្រូវ | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | | |
| ៦.៥.៥ | ប្រើប្រាស់សម្ភារៈអប់រំនិងផ្សព្វផ្សាយប្រកបដោយបរិយាបន្នដើម្បីទាក់ទាញការគាំទ្រដល់កម្មវិធីផ្តល់អាហារតាមសាលារៀន | សម្ភារៈផ្សព្វផ្សាយប្រកបដោយបរិយាបន្នបានប្រើប្រាស់ និងផលិតសម្រាប់ទាក់ទាញការគាំទ្រ | | x | x | x | x | x | x | អ.យ.ក.<br>ក.ជ.គ.ស. | – |
| ៦.៥.៦ | លើកកម្ពស់តម្លាភាពនៃការប្រើប្រាស់ថវិកា ធនធានក្នុងកម្មវិធីផ្តល់អាហារតាមសាលារៀន | របាយការណ៍ចំណូល-ចំណាយ និងការប្រើប្រាស់ធនធានត្រូវបានបិទផ្សាយតាមក្តារខៀនព័ត៌មានគណនេយ្យភាពសង្គម | x | x | x | x | x | x | x | ម.ផ.<br>អ.យ.ក. ដៃគូអភិវឌ្ឍន៍ រដ្ឋបាលថ្នាក់ក្រោមជាតិ | – |
| ៦.៥.៧ | ផ្តល់ការទទួលស្គាល់ និងការថ្លែងអំណរគុណជូនដៃគូអភិវឌ្ឍន៍ វិស័យឯកជនសប្បុរសជន ម្ចាស់ជំនួយ និងសហគមន៍ចំពោះការរួមចំណែកគាំទ្រកម្មវិធីផ្តល់អាហារតាមសាលារៀន | ដៃគូអភិវឌ្ឍន៍ វិស័យឯកជនសប្បុរសជន ម្ចាស់ជំនួយនិងសហគមន៍បានទទួលស្គាល់និងថ្លែងអំណរគុណ | x | x | x | x | x | x | x | អ.យ.ក.<br>រដ្ឋបាលថ្នាក់ក្រោមជាតិ | – |

## ៤. ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត

ការអនុវត្តផែនការសកម្មភាពអនុវត្តគោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀន ២០២៤-២០៣៥ តម្រូវឱ្យមានការរៀបចំក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដូចខាងក្រោម៖

| ល.រ | បរិយាយ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០ |
| **យុទ្ធសាស្ត្រទី១៖ អភិវឌ្ឍក្របខ័ណ្ឌច្បាប់ និងយន្តការ** | | | | | | | | |
| ១.១.១. | រៀបចំប្រកាសស្តីពីការបង្កើតគណៈកម្មការដឹកនាំ និង គ្រប់គ្រងការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ | X | | | | | | |
| ១.១.២. | រៀបចំសេចក្តីសម្រេចស្តីពីការតែងតាំងគណៈកម្មការដឹកនាំ និងគ្រប់គ្រងការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ | X | | | | | | |
| ១.១.៣. | រៀបចំប្រកាសអន្តរក្រសួងស្តីពី ប្រាក់ឧបត្ថម្ភអាហារសិស្ស ប្រាក់ឧបត្ថម្ភចុងភៅ វិធីសាស្ត្រកំណត់ចំនួនសិស្សត្រូវទទួលអាហារនិងចំនួនចុងភៅ និងផ្ទះបាយសាលារៀន ក្រោមកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ | | X | | | | | |
| ១.១.៤. | រៀបចំប្រកាសដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំប្រតិបត្តិកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ | | X | | | | | |
| ១.១.៥. | រៀបចំក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃកម្មវិធីផ្តល់អាហារតាមសាលារៀន | | X | | | | | |

| ល.រ | បរិយាយ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០ |
| ១.១.៦. | ពិនិត្យឡើងវិញក្របខ័ណ្ឌ ពិនិត្យតាមដាន និងវាយតម្លៃកម្មវិធីផ្តល់អាហារតាមសាលារៀន | | | | x | x | | |
| ១.១.៧. | ធ្វើបច្ចុប្បន្នកម្មសៀវភៅណែនាំប្រតិបត្តិកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ដោយផ្អែកលើមេរៀនបទពិសោធន៍ បរិស្ថាន សង្គម និងសេដ្ឋកិច្ច | | | | x | x | | |
| ១.៣.១. | រៀបចំផែនការសកម្មភាពអនុវត្តគោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀនដោយកំណត់សកម្មភាពជាក់លាក់ ធនធាន ពេលវេលា និងការទទួលខុសត្រូវរបស់ក្រសួងពាក់ព័ន្ធ | | | | x | x | | |
| យុទ្ធសាស្ត្រទី២៖ លើកកម្ពស់សន្តិសុខស្បៀងដល់សិស្ស និងគ្រួសារសិស្ស | | | | | | | | |
| ២.១.១. | រៀបចំ ក្របខ័ណ្ឌទិន្នន័យ និងលក្ខណៈវិនិច្ឆ័យស្តង់ដាកំណត់ជ្រើសរើសសាលារៀនគោលដៅ | | | x | | | | |
| ២.១.៣. | រៀបចំសេចក្តីណែនាំស្តីពីការ កំណត់គោលដៅថ្មី និងសកម្មភាព សម្រាប់គាំទ្រការផ្តល់អាហារតាមសាលារៀន | | | x | | | | |
| ២.២.២. | រៀបចំប្រកាសស្តីពីការអនុវត្តថវិកាសម្រាប់ដំណើរការកម្មវិធីផ្តល់អាហារតាមសាលារៀន | | | x | | | | |
| យុទ្ធសាស្ត្រទី៣៖ លើកកម្ពស់ការយល់ដឹងរបស់សហគមន៍ | | | | | | | | |

| ល.រ | បរិយាយ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០ |
| ៣.៣.២. | ជំរុញការកៀរគរការចូលរួមផ្តល់សម្ភារៈ ថវិកា និងកម្លាំងពលកម្មពីសហគមន៍ សម្រាប់គាំទ្រកម្មវិធីផ្តល់អាហារតាមសាលារៀន | x | x | x | x | x | x | x |
| **យុទ្ធសាស្ត្រទី៤៖ លើកកម្ពស់សុខភាព និងអាហារូបត្ថម្ភ** | | | | | | | | |
| ៤.១.១. | រៀបចំស្តង់ដាអាហារូបត្ថម្ភ និងគោលការណែនាំសម្រាប់ក្រុមសិស្សគោលដៅ | | | | x | | | |
| ៤.១.២ | រៀបចំគោលការណ៍ណែនាំស្តីពីការអនុវត្តស្តង់ដាអាហារូបត្ថម្ភ | | | | x | | | |
| ៤.១.១៣. | រៀបចំយុទ្ធសាស្ត្រជាតិ ស្តីពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ | | | | x | | | |
| ៤.២.១. | រៀបចំនិងអនុម័តស្តង់ដាសុវត្ថិភាពម្ហូបអាហារតាមសាលារៀន | | | | x | | | |
| ៤.២.៤. | រៀបចំគោលការណ៍ប្រតិបត្តិ ស្តីពីយន្តការអន្តរាគមន៍សង្គ្រោះបន្ទាន់ឆ្លើយតបទៅនឹងបញ្ហាពុលអាហារតាមសាលារៀន | | | | x | | | |
| ៤.២.៥. | រៀបចំគោលការណ៍ណែនាំស្តីពីសុវត្ថិភាពនិងគុណភាពនៃផលិតកម្ម ដើម្បីលើកកម្ពស់សុវត្ថិភាពស្បៀង ក្នុងខ្សែច្រវាក់ផ្គត់ផ្គង់នៅក្នុងកម្មវិធីផ្តល់អាហារតាមសាលារៀន | | | x | | | | |
| ៤.២.៦. | រៀបចំបែបបទសម្រាប់អនុវត្តប្រព័ន្ធធានាសុវត្ថិភាពម្ហូបអាហារសម្រាប់ការផ្តល់អាហារតាមសាលារៀន កំណត់ហានិភ័យ បង្ការ គ្រប់គ្រង និងតាមដានបញ្ហាទាក់ទងនឹងសុវត្ថិភាពម្ហូបអាហារ ធានាការបញ្ចូលក្នុងផែនការតាមវិស័យ | | | | x | | | |
| ៤.៤.១. | រៀបចំផែនការរយៈពេលមធ្យម កសាង ជួសជុលហេដ្ឋារចនាសម្ព័ន្ធគាំទ្រកម្មវិធីផ្តល់អាហារតាមសាលារៀន | | | x | | | | |

| ល.រ | បរិយាយ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០ |
| ៤.៤.៤. | ធ្វើបច្ចុប្បន្នកម្មគំនូសប្លង់ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ឆ្លើយតបនឹងបម្រែបម្រួលអាកាសធាតុ | | | | x | | | |
| **យុទ្ធសាស្ត្រទី៥៖ ជំរុញការអភិវឌ្ឍកសិកម្ម និងសេដ្ឋកិច្ចក្នុងសហគមន៍** | | | | | | | | |
| ៥.១.៥. | បង្កើត និងដំណើរការប្រព័ន្ធទិន្នន័យទាន់ពេលផ្សារភ្ជាប់ជាមួយអ្នកផ្គត់ផ្គង់និងកម្មវិធី | x | x | x | | | | |
| ៥.២.១. | រៀបចំផែនការសកម្មភាពស្វែងរកការគាំទ្រពីក្រសួង ស្ថាប័នសំខាន់ៗ និងអ្នកពាក់ព័ន្ធ លើការកៀរគរកសិករ និងសហគមន៍ឱ្យផ្គត់ផ្គង់ស្បៀងដល់សាលារៀន | x | x | x | x | x | x | x |
| **យុទ្ធសាស្ត្រទី៦៖ ពង្រឹងអភិបាលកិច្ច ភាពជាដៃគូ និងការសម្របសម្រួលអន្តរវិស័យ** | | | | | | | | |
| ៦.៤.១. | ពិនិត្យឡើងវិញយន្តការប្រព័ន្ធដើម្បីលទ្ធផលអប់រំកាន់តែប្រសើរនៃកម្មវិធីផ្តល់អាហារតាមសាលារៀនដើម្បីពិនិត្យលើការអភិវឌ្ឍសមត្ថភាពជាតិ | | | x | | | | |
| ៦.៥.១. | រៀបចំមគ្គទេសក៍ស្តីពីការលើកកម្ពស់ ភាពជាដៃគូ សម្រាប់ គាំទ្រនិងធានានិរន្តរភាពកម្មវិធីផ្តល់អាហារតាមសាលារៀន | | | x | | | | |
| ៦.៥.៤. | រៀបយុទ្ធសាស្ត្រទំនាក់ទំនងនិងផ្សព្វផ្សាយព័ត៌មានពីការផ្តល់អាហារតាមសាលារៀន | | | | | x | | |

# ៥. តម្រូវការថវិកា

## ៥.១. តម្រូវការថវិកាតាមយុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការសកម្មភាពអនុវត្តគោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀន ២០២៤-២០៣៥ ត្រូវប្រើប្រាស់ថវិកាជាតិតាមក្រសួង ស្ថាប័ន ពាក់ព័ន្ធដែលត្រូវគ្រោងថវិកានៅក្នុងកញ្ចប់ថវិការបស់ក្រសួង ស្ថាប័នសាមីនីមួយៗ និងថវិកាដែលបានមកពីដៃគូផ្សេងៗរួមបញ្ចូលដៃគូរអភិវឌ្ឍន៍ ផ្នែកឯកជន អង្គការសង្គមស៊ីវិល សប្បុរសជន និងប្រភពស្របច្បាប់ផ្សេងៗ។

| ល.រ | យុទ្ធសាស្ត្រ | តម្រូវការថវិកាប៉ាន់ស្មាន (លានរៀល) | | | ប្រភពថវិកា |
|---|---|---|---|---|---|
| | | ២០២៤-២០២៧ | ២០២៨-២០៣០ | ២០៣១-២០៣៥ | |
| ១ | អភិវឌ្ឍក្របខ័ណ្ឌច្បាប់ និងយន្តការ | ៧៨០ | ១៦០ | មិនទាន់បាន ប៉ាន់ប្រមាណ | ថវិការដ្ឋ/ ថវិកាដៃគូ |
| ២ | លើកកម្ពស់សន្តិសុខស្បៀង ដល់សិស្ស និងគ្រួសារសិស្ស | ១៦០,៩២០ | ១២០,៩៤០ | មិនទាន់បាន ប៉ាន់ប្រមាណ | ថវិការដ្ឋ/ ថវិកាដៃគូ |
| ៣ | លើកកម្ពស់ការយល់ដឹង របស់សហគមន៍ | ១៨,៧៩០ | ៥,៨៨០ | មិនទាន់បាន ប៉ាន់ប្រមាណ | ថវិការដ្ឋ/ ថវិកាដៃគូ |
| ៤ | លើកកម្ពស់សុខភាព និងអាហារូបត្ថម្ភ | ៦,៤៦០ | ៤,១២០ | មិនទាន់បាន ប៉ាន់ប្រមាណ | ថវិការដ្ឋ/ ថវិកាដៃគូ |
| ៥ | ជំរុញការអភិវឌ្ឍ កសិកម្ម និងសេដ្ឋកិច្ចក្នុងសហគមន៍ | ៧,៤២០ | ៥,៤៥៥ | មិនទាន់បាន ប៉ាន់ប្រមាណ | ថវិការដ្ឋ/ ថវិកាដៃគូ |
| ៦ | ពង្រឹងអភិបាលកិច្ច ភាពជាដៃគូ និងការសម្របសម្រួល អន្តរវិស័យ | ១,១០០ | ៨១០ | មិនទាន់បាន ប៉ាន់ប្រមាណ | ថវិការដ្ឋ/ ថវិកាដៃគូ |
| សរុប | | ១៩៥,៤៨០ | ១៣៨,២៦៥ | | |
| សរុបរួម | | ៣៣៣,៧៣៥ | | | |

## ៥.២. តម្រូវការថវិកាតាមក្រសួង ស្ថាប័ន

| ក្រសួង ស្ថាប័ន | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ |
|---|---|---|---|---|---|---|---|
| អប់រំ យុវជន និងកីឡា | ៤១,៣៣០ | ៤១,៦១៩ | ៤៣,១៥០ | ៤២,៧៤០ | ៤២,៧១០ | ៤៣,៣៣០ | ២៩៧,៦៨៩ |
| ក្រុមប្រឹក្សាជាតិគាំពារសង្គម | ៤០,០០០ | ៤០,៩៣០ | ៤១,៧១៥ | ៤១,៩៨០ | ៤១,៥១០ | ១,៦៧០ | ២០៩,២៧៥ |
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១,០៦៥ | ១,១០៥ | ១,១៤៥ | ១,១០៥ | ១,១០៥ | ១,១០៥ | ៧,៧៣៥ |
| កិច្ចការនារី | ២០០ | ២០០ | ២០០ | ២០០ | ២០០ | ២០០ | ១៤០០ |
| មហាផ្ទៃ | ៤០ | ៤០ | ៤០ | ៤០ | ៤០ | ៤០ | ២៨០ |
| សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០ | ០ | ៤០ | ៤០ | ៤០ | ៤០ | ២០០ |
| ផែនការ | ០ | ៦០ | ៩០ | ២១០ | ៩០ | ៩០ | ៦៣០ |
| អង្គការដៃគូ | ៨០ | ៨០ | ៨០ | ៨០ | ៨០ | ៨០ | ៥៦០ |

## ៦. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃផែនការសកម្មភាពអនុវត្តគោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀន ជាវិធានការធានាឱ្យការអនុវត្តគោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀនសម្រេចបានតាមគោលបំណងនិងលទ្ធផលរំពឹងទុក។

ផែនការសកម្មភាពអនុវត្តគោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀននេះនឹងត្រូវមានការវាយតម្លៃពាក់កណ្តាលអាណត្តិនៅឆ្នាំ២០២៨ និងវាយតម្លៃបញ្ចប់នៅឆ្នាំ២០៣៥ ដើម្បីវាស់វែង កំណត់ភាពប្រទាក់ក្រឡានៃការអនុវត្តកម្មវិធីស្របទៅនឹងគោលនយោបាយ ប្រសិទ្ធភាព ប្រសិទ្ធផល កម្មវិបាក និងនិរន្តរភាពនៃកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍។ ការវាយតម្លៃទាំងពីរខាងលើជាចំណុចសំខាន់ក្នុងការវាស់វែងភាពជោគជ័យ និងកម្មវិបាកនៃគោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀនដោយ មានការចូលរួមពីភាគីពាក់ព័ន្ធ ជាពិសេសគណៈកម្មការដឹកនាំនិងគ្រប់គ្រងការអនុវត្តកម្មវិធីថ្នាក់ផ្តល់អាហារតាមសាលារៀន។ លើសពីនេះគួរមានការសិក្សាស្រាវជ្រាវ ដើម្បីពិនិត្យស៊ីជម្រៅពីបញ្ហាអាទិភាពរបស់គោលនយោបាយផងដែរ។ ការផ្សព្វផ្សាយ និងចែករំលែកលទ្ធផលការវាយតម្លៃទាំងពីរអាចធានាថាភាគីពាក់ព័ន្ធទាំងអស់ ទទួលបានព័ត៌មានអំពីប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយដែលអនុវត្តបានសម្រេច និងទទួលបានអនុសាសន៍សម្រាប់កែលម្អកម្មវិធី។

បន្ទាប់ពីការវាយតម្លៃពាក់កណ្តាលអាណត្តិបានបញ្ចប់ លទ្ធផល និងអនុសាសន៍នឹងត្រូវត្រួតពិនិត្យរួមជាមួយការអនុវត្ត ផែនការនាពេលបន្ទាប់ដែលគួរមានសកម្មភាពដើម្បីកែលម្អប្រសិទ្ធភាពគោលនយោបាយ បន្ទាប់មកត្រូវអនុម័តផែនការសកម្មភាពដែលបានកែលម្អ។ លទ្ធផលនៃការវាយតម្លៃនិងផែនការសកម្មភាពដែលបានកែលម្អ នឹងត្រូវផ្សព្វផ្សាយជាសាធារណៈទៅកាន់ភាគីពាក់ព័ន្ធ រួមទាំងដៃគូអភិវឌ្ឍ និងវិស័យឯកជនតាមរយៈសិក្ខាសាលាផ្សព្វផ្សាយ និងមធ្យោបាយផ្សេងៗទៀត។

ដូចគ្នានេះផងដែរ ការវាយតម្លៃបញ្ចប់នៅឆ្នាំ២០៣៥ នឹងធ្វើការវិភាគលម្អិតអំពីសមិទ្ធផលសំខាន់ៗ កម្មវិបាក និរន្តរភាពកម្មវិធី និងកំណត់បញ្ហាប្រឈមសំខាន់ៗ ដើម្បីវាស់វែងភាពជោគជ័យនៃគោលនយោបាយ និងការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន។ បន្ទាប់ពីការវាយតម្លៃបញ្ចប់អាណត្តិបានបញ្ចប់ លទ្ធផលនឹងត្រូវបានផ្សព្វផ្សាយដោយមាន

ការចូលរួមពីភាគីពាក់ព័ន្ធតាមរយៈសិក្ខាសាលាផ្សព្វផ្សាយ និងកិច្ចប្រជុំនៅថ្នាក់ជាតិលើលទ្ធផលនៃការអនុវត្តគោលនយោបាយក្នុងពេលកន្លងមក។ របាយការណ៍វាយតម្លៃនេះត្រូវផ្សព្វផ្សាយតាមគេហទំព័រក្នុងទម្រង់ជារបាយការណ៍សង្ខេប។

ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យកម្មវិធីផ្តល់អាហារតាមសាលារៀន អាចប្រើប្រាស់ជាមូលដ្ឋានសម្រាប់តាមដានការអនុវត្ត និងលទ្ធផលនៃកម្មវិធីព្រមទាំងសូចនាករនៃសកម្មភាពដូចមានចែងក្នុងផែនការសកម្មភាពអនុវត្តគោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀន។ ក្រសួង ស្ថាប័ន ពាក់ព័ន្ធដែលជាសមាជិកនៃគណៈកម្មការដឹកនាំ និងគ្រប់គ្រងការអនុវត្តកម្មវិធី ព្រមទាំងភាគីពាក់ព័ន្ធផ្សេងទៀតនឹងប្រើប្រាស់ឧបករណ៍នេះដើម្បីណែនាំ តាមដាន និងវាយតម្លៃសកម្មភាពរបស់ខ្លួនទាំងនៅជាតិនិងថ្នាក់ក្រោមជាតិ។ ឧបករណ៍នេះនឹងជួយវាស់វែងចំពោះវឌ្ឍនភាពនៃផែនការសកម្មភាព។ ប្រព័ន្ធ ឬយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃត្រូវផ្សារភ្ជាប់ជាមួយផែនការនៃការចុះពិនិត្យតាមដាន និងរបាយការណ៍ នៅលើទម្រង់សម្រាប់កត់ត្រាសកម្មភាពចុះពិនិត្យតាមដានផលសម្រេចនៃសកម្មភាពនីមួយៗ។

ការប្រជុំបូកសរុបលទ្ធផលការងារពាក់កណ្តាលឆ្នាំ និងប្រចាំឆ្នាំ ត្រូវរៀបចំជាទៀងទាត់ចាប់ពីឆ្នាំ២០២៥តទៅ ក្នុងគោលបំណងពិនិត្យវឌ្ឍនភាពផ្អែកតាមសូចនាករដែលបានកំណត់ក្នុងយុទ្ធសាស្ត្រនីមួយៗ តាមរយៈការចូលរួមរបស់ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ និងរាយការណ៍ជូនគណៈកម្មការដឹកនាំនិងគ្រប់គ្រងការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន ដើម្បីរាយការណ៍បន្តជូនរាជរដ្ឋាភិបាលកម្ពុជា។

លេខាធិការដ្ឋាននៃគណៈកម្មការដឹកនាំនិងគ្រប់គ្រងកម្មវិធី រួមទាំងមន្ត្រីជំនាញត្រូវបានទទួលការពង្រឹងសមត្ថភាព ដើម្បីធ្វើការសម្របសម្រួលយន្តការនៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងវិធីសាស្ត្រនៃការប្រមូលរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនពីគ្រប់ភាគីពាក់ព័ន្ធ។

កម្មវិធីដែលបានគាំទ្រ ឬអនុវត្តដោយដៃគូអភិវឌ្ឍ សង្គមស៊ីវិល ឬវិស័យឯកជនត្រូវទទួលបានការសហការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដោយក្រសួង ស្ថាប័នទទួលបន្ទុក។ លទ្ធផលការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃត្រូវរាយការណ៍ជូនលេខាធិការដ្ឋានគណៈកម្មការដឹកនាំនិងគ្រប់គ្រងការអនុវត្តកម្មវិធី។ ឧត្តមានុវត្តន៍នៃអន្តរាគមន៍របស់ភាគី

ពាក់ព័ន្ធទាំងនោះ គួរត្រូវបានចងក្រងជាឯកសារធ្វើជាមូលដ្ឋានដល់ក្រសួង ស្ថាប័នក្នុងការពង្រីកកម្មវិធី និងសេវាទាំងនោះស្របតាមលទ្ធភាពថវិកានិងសមត្ថភាពរបស់ស្ថាប័ន។

ក្រសួង ស្ថាប័ន ឬភាគីពាក់ព័ន្ធ ត្រូវកំណត់ផែនការថវិកាលម្អិតនិងសូចនាករតាមកម្មវិធីនិងសកម្មភាពនីមួយៗ ហើយត្រូវរៀបចំជាឯកសារឧបសម្ព័ន្ធ ដើម្បីជាឧបករណ៍តាមដានលទ្ធផលបានអនុវត្តតាមឆ្នាំនីមួយៗ ក៏ដូចជាសម្រាប់វិភាគក្នុងការអនុវត្តផែនការសកម្មភាពបន្តនាឆ្នាំបន្ទាប់។

| លរ. | បរិយាយនៃសកម្មភាពការងារ | ក្របខ័ណ្ឌពេលវេលា | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|
| ១ | ការពិនិត្យឡើងវិញពាក់កណ្ដាលអាណត្តិគោលនយោបាយស្ដីពីការផ្ដល់អាហារតាមសាលារៀន | ២០២៨ | អ.យ.ក. |
| ២ | ការពិនិត្យឡើងវិញចុងអាណត្តិគោលនយោបាយស្ដីពីការផ្ដល់អាហារតាមសាលារៀន | ២០៣៥ | អ.យ.ក. |
| ៣ | បូកសរុបវឌ្ឍនភាពនៃការងារអនុវត្តផែនការសកម្មភាពអនុវត្តគោលនយោបាយស្ដីពីការផ្ដល់អាហារតាមសាលារៀន | ២ដង/ឆ្នាំ | អ.យ.ក. និង ក្រសួង ស្ថាប័ន ពាក់ព័ន្ធ |
| ៤ | របាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីផ្ដល់អាហារតាមសាលារៀនដោយក្រសួងស្ថាប័ន ពាក់ព័ន្ធ | ២ដង/ឆ្នាំ | លេខាធិការដ្ឋាន |

## ៧. ចំណុចផ្តោតផែនការសកម្មភាពតាមដំណាក់កាល

ផែនការសកម្មភាពអនុវត្តគោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀន ដំណាក់កាលទី១ (២០២៤-២០៣០) នេះ ផ្តោតលើការអនុវត្តសកម្មភាពដែលបានព្រមព្រៀង ដូចមានក្នុងយុទ្ធសាស្រ្តរួមផ្ទេរ-ទទួលកម្មវិធីឆ្ពោះទៅកាន់កម្មវិធីជាតិផ្តល់អាហារតាមសាលារៀន។ ជាមួយគ្នានេះដែរ ផែនការជំរុញការកសាងនិងអភិវឌ្ឍសមត្ថភាពគ្រប់កម្រិតគិតចាប់ពីកម្រិតបុគ្គល អង្គភាព និងការសម្របសម្រួលអន្តរវិស័យចំណោមក្រសួង ស្ថាប័ន។

ដំណាក់កាលទី២ (២០៣១-២០៣៥) នឹងផ្តោតលើការពង្រីកវិសាលភាពសាលារៀនអនុវត្តកម្មវិធី ការបង្កើតស្តង់ដា ភាពបត់បែនក្នុងការអនុវត្តកម្មវិធី ការធ្វើទំនើបកម្ម និងបង្កើនការប្រើប្រាស់បច្ចេកវិទ្យានៅគ្រប់ដំណើរការនៃការអនុវត្តកម្មវិធី និងការកសាងមជ្ឈមណ្ឌលឧត្តមភាពក្នុងតំបន់។ ក្នុងដំណាក់កាលនេះ ការបង្កើតកស្តុតាងសម្រាប់សម្រេចចិត្ត ព្រមទាំងយុទ្ធសាស្រ្តកៀរគរការចូលរួមពីមាតាបិតា អ្នកអាណាព្យាបាល សហគមន៍ និងវិស័យឯកជន ក៏ត្រូវបានរៀបចំនិងផ្តល់ការយកចិត្តទុកដាក់ខ្ពស់។

## ៨. សេចក្តីសន្និដ្ឋាន

ផែនការសកម្មភាពអនុវត្តគោលនយោបាយស្តីពីការផ្តល់អាហារតាមសាលារៀន ដំណាក់កាលទី១ (២០២៤-២០៣០) ជាផែនទីបង្ហាញផ្លូវសម្រាប់ចូលរួមអភិវឌ្ឍមូលធនមនុស្សប្រកបដោយសក្តានុពល ដែលមានសុខភាពរឹងមាំ ឈានទៅសម្រេចបាន កាយសម្បទា វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសង្គមកម្ពុជាប្រកបដោយវិបុលភាព ស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា។ ដើម្បីសម្រេចបានចក្ខុវិស័យនេះ តម្រូវឱ្យមានការចូលរួមសហការប្រកបដោយស្មារតី ទទួលខុសត្រូវខ្ពស់ និងមានការយកចិត្តទុកដាក់ពីក្រសួង ស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិគ្រប់កម្រិត។ ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងការសម្របសម្រួលអន្តរវិស័យដើរតួសំខាន់ក្នុងការរួមចំណែករបស់ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធក្នុងការអនុវត្តកម្មវិធីប្រកបដោយនិរន្តភាព។

# ពាក្យកាត់ និងអក្សរកាត់

| អក្សរកាត់ | អត្ថន័យ |
|---|---|
| ក.ក.ជ. | ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ |
| ក.ជ.គ.ស. | ក្រុមប្រឹក្សាជាតិគាំពារសង្គម |
| ក.ជ.អ.ជ. | ក្រុមប្រឹក្សាជាតិស្តីពីអាហាររូបត្ថម្ភជាតិ |
| ក.ន. | ក្រសួងកិច្ចការនារី |
| ក.ស.ក. | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ការិ.អ.យ.ក. | ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក |
| ក.ធ.ស. | ក្រសួងធម្មការ និងសាសនា |
| ផ.ក. | ក្រសួងផែនការ |
| ម.ផ. | ក្រសួងមហាផ្ទៃ |
| មន្ទីរ អ.យ.ក. | មន្ទីរអប់រំ យុវជន និងកីឡាខេត្ត |
| ស.ខ. | ក្រសួងសុខាភិបាល |
| ស.ហ.វ. | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ស.អ.យ. | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| អ.យ.ក. | ក្រសួងអប់រំ យុវជន និងកីឡា |

# សទ្ទានុក្រម

| វាក្យសព្ទ | សេចក្តីពន្យល់ |
| --- | --- |
| កម្មវិបាក/ផលជះ | ផល ឬលទ្ធផលសម្រេចបានពីការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន |
| កាយសម្បទា | រាងកាយរឹងមាំល្អ និងការចម្រើនវ័យសមស្របតាមអាយុ ភេទ ក្រោយពីបានទទួលអាហារូបត្ថម្ភគ្រប់គ្រាន់ |
| ខ្សែប្រវាក់ផ្គត់ផ្គង់ | ប្រព័ន្ធមួយនៃរចនាសម្ព័ន្ធគ្រប់គ្រង មនុស្ស បច្ចេកវិទ្យា សកម្មភាព ព័ត៌មាន និងធនធានដែលត្រូវចូលរួមក្នុងការបញ្ចូលផលិតផល ឬសេវាមួយពីអ្នកផ្គត់ផ្គង់ទៅកាន់អតិថិជន និងអ្នកត្រូវការប្រើប្រាស់។ |
| ចរិយាសម្បទា | អត្តចរិត មនោសញ្ចេតនា ដែលសិស្សានុសិស្សត្រូវចេះប្រកាន់យកក្នុងស្ថានភាពជាក់ស្តែងមួយដើម្បីដាក់ចេញនូវវិធានការឬដំណោះស្រាយសមស្រប និងស្មើភាពជាមួយដៃគូ។ |
| វិជ្ជាសម្បទា | ចំណេះដឹងដែលសិស្សានុសិស្សទទួលបានពីកម្មវិធីអប់រំហើយអាចយកទៅអនុវត្ត ក្នុងជីវភាពប្រចាំថ្ងៃរបស់ខ្លួន |
| បំណិនសម្បទា | ភាពប៉ិនប្រសប់ដែលសិស្សានុសិស្សទទួលបានពីកម្មវិធីអប់រំហើយអាចយកទៅអនុវត្ត ក្នុងជីវភាពប្រចាំថ្ងៃរបស់ខ្លួន |
| បរិយាកាសមេត្រី | បរិយាកាសនៅក្នុងសាលារៀនដែលកុមារអាចរីករាយទទួលទានអាហារបានយ៉ាងមានសុវត្ថិភាព សុខភាពល្អ អនាម័យ បរិយាបន្ន និងមានការគាំទ្រ។ |
| បរិយាបន្ន | ការលើកកម្ពស់ស្ថានភាពរបស់បុគ្គលគ្រប់រូប និងក្រុមនានា ក្នុងការចូលរួមទទួលផលពីសកម្មភាពនានារបស់សង្គមដោយមិនរើសអើងពីពិការភាព ព័ណសម្បុរ សាសនា ជាតិសាសន៍ ស្ថានភាព និងជីវភាពគ្រួសារ ។ |
| បុព្វជិតសាសនា | បុគ្គលជាភ្នាក់ងាររបស់សាសនាក្នុងការរក្សា ការពារ និងផ្សព្វផ្សាយអំពីធម៌វិន័យសាសនា។ |

| | |
|---|---|
| ប្រព័ន្ធធានាសុវត្ថិភាពម្ហូបអាហារ | សំណុំច្បាប់នីតិវិធី និងការអនុវត្តន៍ ដែលត្រូវប្រើប្រាស់ដើម្បីធានាថា អាហារមានសុវត្ថិភាពក្នុងការបរិភោគ នៅគ្រប់ដំណាក់កាលចាប់ពីការដាំដុះ ការប្រើប្រាស់វត្ថុធាតុដើម ការផលិត ព្រមទាំងការចម្អិន និងការចែកចាយអាហារ។ |
| ថាមពលកកើត | ថាមពលដែលបានមកពីប្រភពធម្មជាតិ ដូចជា ពន្លឺព្រះអាទិត្យ និងខ្យល់ជាដើមដែលសុទ្ធតែជាប្រភពមិនចេះរីកស្ងួត និងកកើតឡើងវិញបាន។ ចំណែកឥន្ធនៈហ្វូស៊ីល ដូចជា ធ្យូងថ្ម ប្រេង និងឧស្ម័ន គឺជាធនធានដែលចំណាយពេលរាប់រយលានឆ្នាំដើម្បីកើតថ្មី។ |
| ពិពិធកម្ម | ការធ្វើឱ្យភាពចម្រុះ ឬប្លែកៗ |
| សុវត្ថិភាពម្ហូបអាហារ | ការអនុវត្តដំណើរការធានាថា ម្ហូបអាហារមិនបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់នៅពេលដែលត្រូវបានយកទៅធ្វើការរៀបចំ ឬបរិភោគស្របតាមកម្មវត្ថុប្រើប្រាស់របស់ម្ហូបអាហារនោះ។ |
| ស្តង់ដាម្ហូបអាហារ | ស្តង់ដាផលិតផលជាក់លាក់ និងស្តង់ដាទូទៅដោយរួមបញ្ចូលផងដែរនូវក្រមប្រតិបត្តិគោលការណ៍ណែនាំ។ ស្តង់ដាម្ហូបអាហារនេះ អនុវត្តចំពោះម្ហូបអាហារទាំងអស់ទោះត្រូវបានកែច្នៃស្រេច កែច្នៃពាក់កណ្តាល ឬនៅស្រស់ផៅសម្រាប់ចែកចាយដល់អ្នកប្រើប្រាស់។ |
| ស្តង់ដាសុវត្ថិភាពម្ហូបអាហារ | ច្បាប់ បទដ្ឋានបច្ចេកទេស ឬយោបល់ណែនាំ ដែលត្រូវបានកំណត់ ដើម្បីធានាថា អាហារមានសុវត្ថិភាព ហើយគ្មានសារធាតុគ្រោះថ្នាក់ដែលប៉ះពាល់ដល់សុខភាព។ ស្តង់ដានេះគឺមានគោលបំណង ការពារ និងលើកកម្ពស់សុខភាពសាធារណៈ។ |
| ស្តង់ដាអាហារូបត្ថម្ភ | សេចក្តីណែនាំ ឬលក្ខណៈបច្ចេកទេស ដែលកំណត់ពីប្រភេទ បរិមាណ និងគុណភាពនៃអាហារ និងសារជាតុចិញ្ចឹមដែលត្រូវផ្តល់ ដើម្បីបំពេញតម្រូវការផ្នែកអាហារូបត្ថម្ភសម្រាប់ក្រុមមនុស្សជាក់លាក់មួយ។ |
| សន្តិសុខស្បៀង | ការទទួលបានផ្លូវកាយ សង្គម និងសេដ្ឋកិច្ចរបស់មនុស្សគ្រប់រូបគ្រប់ពេលវេលា ដើម្បីទទួលបានអាហារគ្រប់គ្រាន់ មានសុវត្ថិភាព និងជីវជាតិដែល |

បំពេញតម្រូវការរបបអាហារ និងចំណូលចិត្តអាហារសម្រាប់ជីវិតសកម្ម និងមានសុខភាពល្អ។

**សួនកសិកម្ម** តំបន់ដែលមានការដាំដុះដំណាំ បន្លែ ផ្លែឈើ និងការចិញ្ចឹមសត្វតិច ឬច្រើន ដើម្បីប្រើប្រាស់ក្នុងគ្រួសារ សម្រាប់គោលបំណងអប់រំ ឬប្រើប្រាស់សម្រាប់សហគមន៍។

**ស្តង់ដាអនុវត្តកសិកម្មល្អ** សំណុំស្តង់ដាកសិកម្មដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ដែលគិតដល់ការធានាសុវត្ថិភាពចំណីអាហារ និរន្តរភាពបរិស្ថាន និងសុខុមាលភាពកម្មករក្នុងផលិតកម្មកសិកម្ម។

**ឧត្តមានុវត្តន៍** បណ្ដុំនៃបទពិសោធល្អៗដែលបានមកពីការអនុវត្តកិច្ចការឬបំពេញភារកិច្ចកន្លងមក។